# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៣ ខែមេសា លេខ ៤

ព. ស. ២៤៩៣ – គ. ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ពុទ្ធសាសនានឹងគ្រីស្តសាសនា (សន្និសីទ លោកវេជ្ជបណ្ឌិតមីគូត) (តមក) . . . | លោក ភ៉ាយ - ប៊ុក . . . . . . . | ២៤៤ |
| ពន្លឺអាស៊ីទ្វីប (តមក) . . . . . . . . . | លោក ភ៉ាយ - ប៊ុក . . . . . . . | ២៤៩ |
| សង្គហធម៌ . . . . . . . . . . . . | ព្រះវិន័យធម្ម យូរ - ប៊ុណ . . . . | ២៥៦ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| សារលិខិតនៃលោកស្វាមីវិវេកានន្ទ . . . . | លោក ភ៉ាយ - ប៊ុក . . . . . . . | ២៦៦ |
| ការបណ្តុះនិស្ស័យ (តមក) . . . . . . . | ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៊ម . . | ២៧២ |
| សាវតារវត្តកែវឧតរង្សីហៅរកា . . . . . | ព្រះមហា គុយ - ហួត . . . . . . | ២៨០ |
| បញ្ហាភាសិតដប់ពីរ . . . . . . . . . . | លោក ប៊ូ - ប៉ូ . . . . . . . . . | ២៨៧ |
| រឿងសាមកុក (តមក) . . . . . . . . . | — នូ - កន . . . . . . . . . | ២៩៦ |
| ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) . . | — ឈឹម - ក្រសេម . . . . . | ៣០៦ |
| **កំណត់នឹងប្រវត្តិការណ៍** | | |
| ពិធីបុណ្យប្រគេនព្រហ្មទានចំពោះព្រះសង្ឃ ៨៨ រូប . ដែលប្រឡងជាប់សញ្ញាបត្រ សាលាបាលី ជាន់ខ្ពស់ . . . . . . . . . . . . | សមាគមមិត្តសាលាបាលី . . . . | ៣១០ |

មួយឆ្នាំមាន ១២ សៀវភៅ ដំឡៃជា៖ . . . . . . . . . . . . . ១៤៥៛,០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES

### PARTIE RELIGIEUSE

Pages


Bouddhisme et Christianisme (Conférence du Docteur André Migot) ... *M. RAY-BUC* ... 244

La Lumière de l'Asie (suite) ... *M. RAY-BUC* ... 249

SANGAHADHARMA ... *Préah Vinayadhamma YOU-PONN* ... 256


### PARTIE LITTERAIRE


Message du Swami VIVEKANANDA ... *M.RAY-BUC* ... 266

L'Education morale (suite) ... *Préah moha PEUNG-PAM* ... 272

Historique de la pagode de KEO NABARANSI dite ROKAR ... *Préah moha KUY-HUOT* ... 280

Douze expressions proverbiales khmères ... *M.BOU-PO* ... 287

Histoire de SAMKOK (suite) ... *Oknha NOU-KAN* ... 296

Histoire du Royaume du Cambodge (suite ... *Oknha CHHIM-KRASEM* ... 306


### NOTES ET CHRONIQUES


Fête de la distribution des prix aux 88 bonzes lauréats du concours de sortie de l'Ecole Supérieure de Pâli ... *Association des Amis de l'Ecole de Pâli* ... 310


Prix l'abonnement annuel comprenant 12 numéros: 145$00

# សព្ទសាធុការពរឆ្នាំថោះត្រីស័ក ព. ស. ២៤៩៤

## គ. ស. ១៩៥១

ឆ្នាំថោះត្រីស័កពុទ្ធសករាជ ទ្វេ ចតុ នព្វ ជាបដល់ ចត្វា
គ ស. ឯក នព្វ បញ្ច ឯកា សង្ក្រាន្តខេមរាចូលដល់ថ្កាន ។
ពុទ្ធសាសនបណ្ឌិត្យ ប្រសិទ្ធិពរថ្វាយជូនសព្វឋាន
ដល់ជាតិសាសនាក្សត្រកល្យាណ នៃខ្មែរឲ្យបានក្សាន្តសុខា! ។
សូមព្រះប្រិយមហាក្សត្រ និរទុក្ខវិបត្តិនិរសោកា!
សូមក្រុមព្រះរាជញាតិវង្សា មានមហេសក្ខាជោគសិរី! ។
សូមក្រុមរាជរដ្ឋាភិបាល ចាត់ការពិសាលគប់សួស្តី
បំពេញកិច្ចការកែតផែនដី ឲ្យមានសេរីកុំបីធុក! ។
សូមបណ្តារាស្ត្រកម្ពុជា មានជោគជយាចំរើនសុខ
សាមគ្គីឯកច្ឆន្ទជាប្រមុខ គ្រងរក្សាទុកវង្សវរ្ម័ន! ។

# ពុទ្ធសាសនានិងគ្រិស្តសាសនា

## សន្និសីទលោកម៉ីគូត

លោក ពៃ-ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យភ្នំពេញ

ប្រែពីទស្សនាវដ្តី "ហ្វ្រង់អាស៊ី" ខែមិថុនា ឆ្នាំ ១៩៥០

(តមក)

---

ម្នាលភិក្ខុទាំងឡាយ ទុក្ខសមុទយអរិយសច្ចនោះ គឺតណ្ហាដែលនាំ ធ្វើឲ្យសត្វបដិសន្ធិវិលចុះវិលឡើង កើតស្លាប់ៗកើត ហើយមានសេចក្តី ត្រេកត្រអាលនឹងលោកៈ មានសេចក្តីស្រេកឃ្លានក្នុងលោកាមិសៈ មាន សេចក្តីស្រេកឃ្លានក្នុងលោកកត មានសេចក្តីស្រេកឃ្លាននូវសេក្ខងកត មានសេចក្តីស្រេកឃ្លានក្នុងអនិច្ចតាធម៌ ។

ម្នាលភិក្ខុទាំងឡាយ ទុក្ខនិរោធអរិយសច្ចនោះ គឺ កិរិយារលត់បង់នូវ តណ្ហា, ការលះបង់នូវតណ្ហា, កិរិយារំលុតស្រឡះអំពីតណ្ហាទាំងអស់ ។

ម្នាលភិក្ខុទាំងឡាយ ផ្លូវប្រតិបត្តិដើម្បីនាំឲ្យដល់នូវកិរិយារលត់ទុក្ខ នោះ គឺ សម្មាទិដ្ឋិ, សម្មាសង្កប្បោ, សម្មាវាចា, សម្មាកម្មន្តោ, សម្មា-អាជីវោ, សម្មាវាយាមោ, សម្មាសតិ, សម្មាសមាធិ[១] ។

ហេតុដែលនាំឲ្យកើតបាបនៅក្នុងខ្លួនយើង គឺ តណ្ហា, តណ្ហានេះ កើតមកអំពីអវិជ្ជាៗ ធ្វើឲ្យយើងភ័ន្តច្រឡំយល់ថា លោកដែលមានសភាព

---

១ មហាវគ្គ ។

មិនពិតជាជាពត់ទៅវិញ ; ត្រូវតែយើងយល់ថា ទុក្ខនេះមិនមែនជាបញ្ហាដែលត្រូវដោះស្រាយចំពោះបុគ្គលដោយបុគ្គលនេះអាចរកសេចក្ដីសុខឃើញទេ ។ ព្រោះសេចក្ដីសុខច្រើនបានផលជាទុក្ខចំពោះខ្លួនយើង ឬចំពោះអ្នកដទៃ សុខនោះប្រកបដោយចរភាព (fugitif) មានឧសថពុល ឬសភាពកំផែក គឺសេចក្ដីខ្លាចក្រែងសុខនោះបាត់បង់ទៅវិញឬការទស្សនានូវសេចក្ដីទុក្ខអ្នកដទៃ ដែលនាំមិនឲ្យយើងសោយសេចក្ដីសុខចំពោះខ្លួនបានស្រួល ។ ទុក្ខនេះគេត្រូវពិចារណាទៅតាមបញ្ហាជាសាកល; ទុក្ខនេះមិនមែនទុក្ខចំពោះបុគ្គលម្នាក់ៗ គឺទុក្ខចំពោះសាធារណៈទូទៅទាំងអស់ ព្រោះបើតាមពិតគឺជាទុក្ខសាកល ។

ចំពោះពួកបូព៌ាជាតិ, ការដែលនាំឲ្យស្ថានភាពនោះកាន់តែលំបាកយល់ គឺជំនឿត្រង់វដ្ដសង្សារ (transmigration) ។ ជីវភាពបច្ចុប្បន្នរបស់យើង គឺមិនមែនជាការពិសោធន៍ប្រកបដោយអនិច្ចតា ដែលមានស្ថានសួគ៌ជាផលនោះទេ ព្រោះជីវភាពនោះមានដំណើរជាប់តៗ គ្នាទៅកាន់ជីវភាពមួយថ្មីនឹងសេចក្ដីទុក្ខជាថ្មី ។ គេអាចយល់បានថាការខ្នះខ្នែងមានសារៈសំខាន់បំផុតនៃពួកបូព៌ាប្រទេស គឺមានបំណងចង់ចាកចេញពីវដ្ដដ៏លាមកនោះ ដែលនាំសត្វឲ្យវិលកើតស្លាប់ ចៀសវាងនូវសេចក្ដីកើតដើម្បីកុំឲ្យសោយនូវទុក្ខប្រាថ្នាឲ្យផុតស្រឡះពីទុក្ខនោះជាស្ថាពរ គឺព្រះនិព្វានជាអវសានផុតពីវដ្ដ ។

បើតាមពណ៌នាខាងលើនេះ, អ្នកដែលបានឃើញអាកប្បកិរិយាពីរយ៉ាងមានសភាពផ្ទុយគ្នាចំពោះជីវភាព គឺពួកបច្ចិមជាតិពោលថាជីវភាពជាវត្ថុល្អ ហើយសេចក្ដីទុក្ខគឺការបាត់បង់នូវជីវភាពនោះ, ពួកបូព៌ាជាតិថា ជីវភាពជាវត្ថុអាក្រក់ ហើយសេចក្ដីសុខគឺការលែងមកកើតទៀត ។ តាមយោបល់, ការយល់ផ្ទុយគ្នាដូចនេះ នាំឲ្យបានផលដ៏សំខាន់បំផុត គឺជាហេតុឲ្យពួកបូព៌ាជាតិចាកចេញពីជីវភាពក្រៅ ពេញចិត្តនឹងជីវភាពក្នុងការស្អប់ខ្ពើមនូវកម្មិកភាព សម្ភារៈនេះជាហេតុឲ្យពួកបច្ចិមជាតិមានឋាមភាព, ការពេញចិត្តខាងកម្មិកភាពដែលកើតមកពីវិចារណធម៌ ព្រមទាំងផលដែលបានមកពីការពិចារណា ដោយចក្ខុប្រសាទនឹងបញ្ញា, សភាវគតិនៃការរំលោភ, គ្មានសេចក្ដីសន្ដោស, ពេញចិត្តខាងការតស៊ូនឹងធ្វើសង្គ្រាម ។ យើងនឹងពណ៌នាហេតុមួយទៀតនៃនិន្នាការនោះតទៅខាងក្រោយ ។

ច្បាប់ពុទ្ធសាសនាដែលពណ៌នាពីទុក្ខនោះ នាំឲ្យគេយល់ថាពុទ្ធសាសនាមានលក្ខណៈលាមកបំផុតថា ពួកបូព៌ាជាតិជាពួកអតេកិច្ឆបុគ្គល (fataliste) ។ គេជាសភាពលាមកឬដោយបានពិសោធន៍ឃើញវត្ថុនោះមិនពិតគឺយើងដឹងពិតដោយខ្លួនឯងនូវបាបអកុសលទាំងនោះ មិនមែនបណ្ដោយឲ្យបាបអកុសលនោះ ចូលមកលុកលុយក្នុងសន្ដានចិត្តយើងទេ ឬបន្ទុំយើងដោយពណ៌នានូវហេតុដ៏សុខុមដែលមិនអាចយកមកពិសោធន៍

ឲ្យឃើញជាក់ស្តែង តែដើម្បីនឹងតស៊ូបំផ្លាញសភាពលាមកនោះឲ្យសាបសូន្យ? តើជាសភាពលាមក ឬគ្រូពេទ្យដែលពិនិត្យសមុដ្ឋាននៃបហក-រោគ (tuberculose) ដំបៅ (cancer) ហើយរកមធ្យោបាយ ដើម្បីនឹងតស៊ូ ដើម្បីរំងាប់នូវរោគនោះ? គឺជាសភាពផ្ទុយទៅវិញដោយបង្ហាញអាកប្ប-កិរិយាដូចខាងលើនេះ, គេទុកជាសោភណភាព (optimisme) ដ៏ក្រៃលែង ដែលមានលក្ខណៈផ្ទុយគ្នានឹងការទទួលទុកដោយខន្តីធម៌ ។

ព្រោះហេតុដូចនេះ, ពួកក្រជាង (គ្រិស្តសាសនិកជន) ជាពួកអតេកិច្ចបុគ្គលដែលយល់ដូចលោកសង្ឃខាងគ្រិស្តសាសនា លោកសាំងអូកស្តាំង ឬលុថែរជាដើមថាជឿជាក់ត្រង់បុព្វាសនា (prédestination) ដែលយល់ថា សេចក្ដីសុខនឹងទុក្ខមានអាទិទេពជាក់កំរិតស្រេចជាអនន្ត-កាល មុនកិច្ចដែលយើងប្រព្រឹត្តល្អនោះទៅទៀត ។ បើដូចនេះ តើមានប្រយោជន៍អ្វីក្នុងការតស៊ូនឹងទុក្ខ បើគ្មានសេចក្ដីអនុគ្រោះពីអាទិទេព ។ បានធ្វើអនុគ្រោះចំពោះបុគ្គលតាមទំនើងចិត្តរបស់លោក ដែលយើងមិនមានសមត្ថភាពអាចទទួលបានដោយការប្រព្រឹត្តល្អចំពោះខ្លួន,[១] យើង

១ សញ្ញាណនៃលទ្ធិលោក សាំង-អាកុ. បស្តាំងចំពោះសេចក្ដីអនុគ្រោះនិងទិដ្ឋិវិបត្តិ តឺជក ស្រង់ៈស៊ូរតែពាខអត្ថបទ ក្នុងសៀវភៅ.បស់លោកប៉ែរពួរ៉ា (Père Pourrat) ឆាទជាស្ដីរ ទុយអាលីតេក្រេបេឥ, ក្បាលទី ៤ ភាគ ២ ទំព័រ ២-៣ សៀវភៅមាឥបុះសេចក្ដីអនុញ្ញាតឲ្យបោះពុម្ព ហើយជាកិច្ចត្រូវគ្នានឹងសម្មាទតិនៃពួកកាតូលិក ។

មិនអាចប្រព្រឹត្តបុណ្យកុសល ឬមានបំណងចង់ចូលដោយសេរីចំពោះសាសនាណាដែលយើងពេញចិត្ត ឬយើងមិនអាចដោះខ្លួន ឲ្យចេញពីទុក្ខបាន ។ នេះជាទ្រឹស្តីមួយដែលនាំមនុស្សទៅកាន់អតិកិច្ចលទ្ធិ (fatalisme) ហើយគួរឲ្យឆ្ងល់ពេកណាស់ ក្នុងរឿងនេះដោយថា ពួកគ្រិស្តសាសនិកជនពោលពាក្យបន្ទោសនិន្ទាដល់ពួកពុទ្ធសាសនិកជនទៅវិញ ! ចំណែកខាងពួកពុទ្ធមាមកជនមានសេចក្ដីទុក្ខលំបាក ដោយជីវភាពក្នុងបច្ចុប្បន្ននេះ ដែលជាលទ្ធផលនៃកម្មិកភាពរបស់យើងពីជីវិតអតីត; យើងមិនអាចឲ្យអ្នកដទៃទទួលការខុសត្រូវក្រៅពីខ្លួនយើង តែយើងអាចប្រែកែនូវវាសនារបស់យើងទៅតាមបំណង ព្រោះយើងជាគ្រូលើវាសនារបស់យើងហើយ ។ ជីវភាពអនាគតរបស់យើង ជាផលនៃកម្មិកភាពដែលយើងធ្វើក្នុងបច្ចុប្បន្នដោយជីវភាពដ៏បរិសុទ្ធ ព្រោះមិនបានធ្វើដល់សត្វលោកព្រមទាំងផ្សាយចិត្តសប្បុរសជុំវិញយើង, យើងអាចស្ថាបនាបានសុគតិភាពក្នុងអនាគតចំពោះខ្លួនយើងនិងអ្នកដទៃ; ដោយជីវភាពរបនាត ៗ ជាច្រើនជាតិ បំណងទៅកាន់សុក្រិតភាព យើងអាចចាកចេញពីវដ្តសង្សារទៅកាន់ព្រះនិព្វានបាន ។

(មានត)

# វគ្គទី ៦

## La Lumière de l'Asie

លោក ស៊ើរ-អេតវ៉ិន អារណូលដ៍ តែង

## លោកឧកញ៉ា-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

តែនាងបានគោរពយើងៗ សូមគោរពនាងវិញ ដោយនាងមានចិត្តដ៏ថ្លៃថ្លាមកកាន់យើង ហើយនាងបានស្គាល់នូវផ្លូវដោយសភាវគតិ ប្រៀបដូចជាសត្វព្រាបញីដែលហើរទៅកាន់សំបុកដោយសេចក្ដីស្នេហា ៗ នាងបានបង្ហាញថា សេចក្ដីសង្ឃឹមនៅក្នុងមនុស្សគ្រប់រូបហើយកងចក្រនៃជីវភាពគឺនៅក្រោមទុក្ខទោសនៃធន្ធៈរបស់មនុស្សទាំងអស់ ៗ សូមសេចក្ដីសុខស្និតនៅនឹងនាង ហើយវេទនាជីវភាពនាងទៅកាន់សេចក្ដីស្រួលសប្បាយចុះ! សូមឲ្យយើងបង្ហើយនូវករណីយកិច្ចរបស់យើងដូចនាងបានបំពេញករណីយកិច្ចរបស់នាង! អ្នកដែលនាងស្មានថាព្រះនោះ សូមឲ្យនាងទទួលនូវពរទាំងអស់នេះចុះ! ៗ

នាងសុជាតាទូលតបទៅព្រះបរមពោធិសត្វវិញថា "សូមព្រះអង្គបានសម្រេចនូវព្រះបរមសម្មាសម្ពោធិញាណ តាមព្រះរាជបំណង" ហើយនាងក្រឡេកមើលដោយមុទុតាចិត្តទៅបុត្រនាងដែលលើកដៃតម្រង់

ទៅរកព្រះបរមពោធិសត្វ ប្រហែលជាដឹងដូចទារកដឹងក្តីជាច្រើនហើយ ជាអាការដែលយើងមិនអាចយល់បាន, ដៃទារកនោះធ្វើអញ្ជលីគោរពព្រះបរមពោធិសត្វ ៗ ព្រះពោធិសត្វទ្រង់តើនឡើង មានព្រះកាយពលបរិបូណ៌ ដោយបានសោយនូវព្រះក្រយាហារដ៏មានឱជារស ហើយទ្រង់ត្រាច់ត្រម៉ង់ទៅកាន់រុក្ខជាតិមួយដើមធំគឺដើមពោធិ (Bodhi) [១] ព្រឹក្សជាតិនេះតាំងពីនោះមក មិនបានស្ងួតស្រពោន នៅស្ថិតស្ថេរជាដរាប ទុកដូចជាកិត្តិយសរបស់ធម្មជាត ៗ គឺនៅក្រោមម្លប់ព្រឹក្សជាតិដែលមានសាខាត្រសុំត្រសាយនេះហើយ ដែលព្រះអង្គបានសម្រេចនូវពុទ្ធនិស្ស័យឃើញច្បាស់នូវធម៌អរិយសច្ច ; ក្នុងពេលនោះ ព្រះបរម-គ្រូ បានជ្រាបច្បាស់នូវព្រឹត្តិការណ៍ទាំងប៉ុន្មាន ; ព្រោះហេតុដូចនេះព្រះអង្គបានធ្វើពុទ្ធដំណើរទៅខាងមុខ ដោយព្រះដំហានឈានយ៉ាងមាំមួនប្រាកដហើយប្រកបដោយអច្ឆរិយភាពគួរជាទីគោរព, មានព្រះភ័ក្ត្រឈមទៅកាន់ព្រះពោធិព្រឹក្សនោះ ៗ ឱលោកសន្និវាសអើយ ! ចូរអ្នកធ្វើចិត្តឲ្យសប្បាយរីករាយចុះ ៗ ព្រះបរមពោធិសត្វស្តេចបានយាងទៅដល់ក្រោមព្រះមហាពោធិហើយ, កាលណាព្រះអង្គទ្រង់បានត្រាច់ចូលទៅក្រោមម្លប់ត្រឈឹងត្រឡៃ, ក្រោមបុសដែលមានសភាពសំយុងពេន

---

១ Pipal ficus religiosa គេបានឃើញក្នុងសម័យបច្ចុប្បន្ន នៅពុទ្ធគយា (ខេត្តប៊ីហារ) ។ ព្រឹក្សជាតិនេះហើយដែលព្រះសិទ្ធត្ថទ្រង់គង់នៅទៀបគល់វាត្រាស់សម្មាសម្ពោធិញ្ញាណ ។

ពន្លចុះមានសភាពមូលវែង ដូចជាសសរក្រោមស្លឹកក្រុកជាតិនោះ ដែលធម្មជាតរចនាជាសភាពមូលមានពណ៌ខៀវស្រស់ក្តី, ព្រះធរណីហាក់ដូចជាបានក្រាលបន្ទូវព្រះទ័យព្រះអង្គ បានធ្វើឲ្យតិណជាតិដុះដូចជាសក់វែងអន្លាយស្រស់ទីងបុប្ផារីកស្គុះស្គាយនៅក្រោមព្រះបាទាព្រះអង្គ ។ មែកក្រុកជាតិទាំងនោះឱនទន់ទោរ ដើម្បីនឹងការពារព្រះរូបព្រះអង្គ ; ទេវតាគង្គាបានឲ្យបក់ផាយផាត់គន្ធពិដោរនៃបុប្ផាបទុមក្រអូបឈ្ងុយឈ្ងប់ពីស្ទឹងនោះ មានសភាពត្រជាក់ស្រួលសប្បាយ ៗ មានវនរ៉ាសីសត្វដូចខ្លារខិន, ជ្រូកព្រៃនឹងប្រើសបើកភ្នែកធំ ៗ បែបដូចជាឆ្ងល់ តែរស់នៅជាសុខក្នុងអភិទោសសម័យថ្ងៃនោះ, ហើយឈរពីគុហា ឬគុម្ពោតព្រៃក្រឡេកមើលទៅព្រះភ័ក្ត្រព្រះពោធិសត្វ ។ ពស់ដែលមានពិសចាកចេញពីរន្ធត្រជាក់, ធ្វើក្បាលងើបចុះឡើងគោរពដល់ព្រះពោធិសត្វ ; មេអំបៅមានពណ៌គ្រប់យ៉ាងហិចហើរសន្ធឹងស្លាបពណ៌ខៀវផ្ទៃមេឃ ខៀវស្រស់ដូចស្លឹកឈើ ឬសុវណ្ណពណ៌ដើម្បីនឹងបក់ផ្លិតកុំឲ្យព្រះអង្គក្តៅ បក្សាស៊ុំងទំលាក់ចោលនូវរំពាហើយស្រែកយំ ៗ សត្វកណ្ដុរនៅតាលវែនមានរូបភាពគំនូរឆ្នូតពណ៌ លោតពីមែកក្រាមួយទៅមែកក្រាមួយទៀត ហើយឈ្ងៀងភ្នែកមើលចំទៅព្រះអង្គ ; បក្សាចាប (Oiseau tisserand) យំនៅមាត់សំបុក, សត្វបង្កួយរត់, បក្សាកូអិល ( Koïl ) ប្រហែលជាបក្សាករវិកបញ្ចេញសំឡេងពីរោះអស្ចារ្យ, លលកទ្រាំង

ហើរប្រទក្សិណជុំវិញព្រះអង្គ សូម្បីតែពួកទុរង្គសត្វ ក៏មានសណ្ឋានចិត្តសប្បាយរីករាយដែរក្នុងពេលនោះ ៗ ព្រះធរណីនិងព្រះពាយបញ្ចេញសំឡេងពីរោះមូលតែមួយថា “ព្រះអង្គជាទីស្រឡាញ់ពេញចិត្តនៃសត្វលោក, ទ្រង់ជានិយ្យានិកបុគ្គល មានព្រះទ័យអាណិតអាសូរដល់សត្វ-លោក, ទ្រង់ដែលបានផ្តាញ់នូវទោសៈ, លោភៈ, តណ្ហា, សភាពខ្វាបទឹងវិចិកិច្ឆា, ទ្រង់ដែលបានយកព្រះទ័យព្រះអង្គធ្វើពលិកម្ម ដើម្បីប្រយោជន៍ផ្ទាល់ព្រះអង្គនិងប្រយោជន៍សត្វលោកទាំងអស់ សូមអារាធនាទ្រង់និមន្តទៅកាន់អជ្ជបាលនិគ្រោធចុះ ! លោកដែលប្រកបដោយទុក្ខសូមថ្វាយពរសព្ទសាធុការ ដល់ទ្រង់ដែលនឹងបានត្រាស់នូវអនុត្តរ-សម្មាសម្ពោធិញ្ញាណក្នុងកាលខាងមុខ ដែលស្រោចស្រង់សត្វនិករឲ្យផុតពីកំណាប់ដៃនៃតណ្ហា ! ឱទ្រង់ដែលជាទីគោរពដ៏វិសេស, សូមទ្រង់ស្តេចយាងទៅតស៊ូនឹងមារាធិរាជឲ្យបានជោគជ័យ ! ឱមហារាជដែលប្រកបដោយទសពលញ្ញាណ, ពេលវេលាដល់ហើយ នេះគឺពេលសទ្ធិប្រកាសដែលសត្វលោករង់ចាំ !” ៗ

ក្នុងពេលនោះ ព្រះបរមពោធិសត្វទ្រង់កំពុងគង់នៅក្រោមម្លប់ពោធិព្រឹក្ស ៗ ចំណែកមារាធិរាជបានប្រាបថា “ព្រះពោធិសត្វទ្រង់គង់នៅទីនោះ, ព្រះអង្គត្រូវជួយស្រោចស្រង់ នូវមនុស្សលោកឲ្យផុតពីកណ្តាប់ដៃនៃតណ្ហាហើយ, ពេលវេលាដែលព្រះអង្គត្រូវស្វែងរកធម៌ពិត

ជួយស្រោចស្រង់សត្វលោកដល់ហើយ" ដូច្នេះ ក៏បង្គាប់ទៅសេនា ខាង
បាបអកុសល ៗ ម៉្លោះហើយពួកអារក្សដែលជាសត្រូវនឹងបណ្ឌិត ព្រម
ទាំងធម្មជាតិក៏ស្វាង បានចាកចេញពីបាតាលមកប្រជុំគ្នា គឺ អរតិ, តួស្ណា
(តណ្ហា), រាគៈ ហើយនឹងវេហ៍ពលនៃតណ្ហា, ឧត្តាសៈ (horreur)
អវិជ្ជា, កាមៈ (Concupiscence) ព្រមទាំងសេនានៃអន្ធការនឹងភ័យ,
ទាំងអស់ព្រួតគ្នាស្អប់ព្រះពោធិសត្វ ហើយរកឧបាយនឹងបំភ័ន្តព្រះប្រាជ្ញា
ព្រះអង្គ; ហើយក្នុងចំណោមពួកបណ្ឌិតក៏គ្មានអ្នកណាអាចដឹងបាន តើ
ពួកអារក្សនៅស្ថាននរកនោះនឹងតស៊ូបែបណា ដើម្បីនឹងបំភ័ន្តព្រះប្រាជ្ញា
ព្រះពោធិសត្វ កុំឲ្យរកឃើញសច្ចធម៌នោះ ៗ ជួនកាលបណ្ដាលកេវកាព
ជាព្យុះសង្ឃរា, កងពលនៃអារក្សទាំងនោះ បានអធិស្ឋានបង្កើតជាសត្វ
ស្បូវផ្គរលាន់ព្រួតពង់គឹកកងពេញមេឃ ហើយមានផ្លេកបន្ទោរភ្លឺចាំងថែង,
ស្ទើរខ្វាក់ភ្នែក ប្រៀបដូចស្រូវសាលីដែលរាត់រាយនៅក្នុងស្រែ មិនទាន់
ចងជាកណ្ដាប់ គេយកទៅរាយពេញនភាល័យមានពណ៌ក្រហម; ជួន
កាលប្រើឧបាយកលអធិស្ឋានជាសត្វសំឡេងពីរោះពីសារគួរឲ្យសវនា;
អារក្សទាំងនោះ បានប្រតិស្ឋានកណ្ដាលស្ទឹករក្ខោស្ងៀមស្ងប់ នឹងសំឡេង
ចេញសម្ផស្សនូវរូបភាពមានលំអគួរឲ្យជាប់ចិត្ត ចេះច្រៀងសំឡេងពីរោះ
គួរជាទីអស្ចារ្យគួរស្នេហា ហើយខ្សឹបគ្នាពីកាមារម្មណ៍ផ្សេងៗ, សេចក្ដី
ត្រេកត្រអាលគ្រប់យ៉ាង; ជួនកាលពួកសេនាមារនោះធ្វើកលល្បិចថ្វាយ

អំណាចទៅព្រះពោធិសត្វ; ដូនកាលប្រែខុបាយកលសង្ស័យ, ពួកពលមារបានបង្ហាញឲ្យជាក់ច្បាស់ចំពោះព្រះភក្ត្រព្រះអង្គថា សច្ចធម៌ជាវត្ថុគ្មានសារប្រយោជន៍អ្វីឡើយ ។

សង្គ្រាមទាំងនោះ តើជាសភាពខាងក្រៅហើយអាចមើលឃើញដោយមំសចក្ខុ ។ ព្រះពោធិសត្វតស៊ូកងព្រះទ័យចំពោះមារនឹងពលមារទាំងនោះ? ។ ត្រូវពិចារណាដូចនេះ ខ្ញុំសូមពិណនារឿងនោះតាមដែលខ្ញុំបានឃើញចារិកទុកក្នុងគម្ពីរ ។

កិលេសទាំងដប់មកដល់ គឺពួកមិត្តដែលមានវិទ្ធានុភាពរបស់ស្ដេចមារាធិរាជ មិច្ឆាទេវតា ។ ដំបូងគឺអត្តវាទ (ឬហៅថាអត្តានុវាទ), បាបអកុសលខាងអត្តទដ្ឋភាព (le pèché de l'Egoïsme) ដែលមានចិត្តទស្សនាទៅកាន់រូបរបស់ខ្លួនដែលប្រតិស្ឋានក្នុងៈបាំងដូចកញ្ចក់ នៅកណ្ដាលចក្រវាឡហើយស្រែកថា: "អញ" ចង់ឲ្យលោកសន្និវាសនេះពោលថា: "អញ" ហើយចង់ឃើញសត្វលោកទាំងអស់វិនាស ហើយពោលថា: បើទ្រង់នឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ, ទ្រង់ត្រូវបោះបង់សត្វលោកឲ្យវង្វេងនៅទីងងឹតអន្ធការ; ទ្រង់ត្រាស់ដឹងតែខ្លួនទ្រង់បានហើយ" ហើយបន្លឺនូវសីហនាទថា: "ទ្រង់គេងឡើង, ហើយទតនូវសេចក្ដីសុខក្នុងទេវលោក, សុខដែលគ្មានប្រែប្រួល, គ្មានកង្វល់, គ្មានសង្គ្រាម" ។ ព្រះបរមពោធិសត្វតបថា: "នៃពលមារ! អ្នកឯងស្អប់

ទ្តើមយុត្តិធម៌ ប្រកាន់យកអយុត្តិធម៌ដែលឲ្យនូវទុក្ខទោសភ័យគ្រប់យ៉ាង វិញ ; អ្នកចូរទៅបោកប្រាសអ្នកស្នេហាចំពោះខ្លួនឯងឯណោះចុះ " ។

តមក វិចិកិច្ឆាមានមុខស្ទឹតស្ទាំង ជាអកុសលខាងពោលពាក្យ សំដីឡកចំអក ស្រែកសំឡេងដូចកញ្ជ្រែទៅរកព្រះបរមពោធិសត្វថា "វត្តទាំងអស់សុទ្ធតែមិនទៀង, ជាសភាពទទេគ្មានខ្លឹមសារ ហើយវិជ្ជា ដែលបានមកពីសភាពសោះសូន្យដូច្នេះ ក៏គ្មានប្រយោជន៍អ្វីឡើយ; ព្រះអង្គស្វែងរកតែស្រមោល: សូមព្រះអង្គតើនឡើងហើយយាងចេញ ពីទីនេះ; មិនមានមធ្យោបាយអ្វីក្រៅពីខន្តីធម៌, មិនមានអ្វីជាទីសង្ឃឹម ចំពោះមនុស្ស ដោយគ្មានអ្នកណាអាចបញ្ឈប់កង់ចក្រលោកដែលវិល ជានិរន្តរកាលបាន " ។ ព្រះបរមពោធិសត្វឆ្លើយតបទៅនឹងវិចិកិច្ឆាវិញ ថា: "អ្នកមិនត្រូវមករវល់នឹងយើងក្នុងរឿងនេះទេ, វិចិកិច្ឆាអ្នកបោក ប្រាស! អ្នកជាបច្ចាមិត្ត ឬជានីវរណធម៌ដ៏សុខុមចំពោះមនុស្ស " ។

ពលមារទីបី គឺអកុសលដែលប្រគល់បុគ្គានុភាពទៅលទ្ធិក្រៅ សាសនាឬពាហិរសាសនា ជាលទ្ធិប្រកបដោយអវិជ្ជា គឺ សីលព្វតបរ-មាសៈ ជាមេអាចបន្ទុំផ្សាយនូវប្រទេសជាច្រើនឲ្យមានសទ្ធាជ្រះថ្លាដោយ ចិត្តសន្តោសបោកសត្វលោក ឲ្យធ្វើពិធីផ្សេងៗ, សូត្រធម៌គ្រប់យ៉ាង ហើយជាអ្នកកាន់កូនសោខ្លួនឯង សម្រាប់បិទទ្វារនរក ហើយបើកទ្វារ នៃឋានសួគ៌ ។

(មានត)

# សង្គហធម៌

## ព្រះវិន័យធម្ម យូរ-ប៉ុណ្ណ

ក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ

ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ៨ កើតខែភទ្របទ

ឆ្នាំកុរនព្វស័ក ព. ស. ២៤៩០

---

នមោ តស្ស ភគវតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះ អាត្មាភាពនឹងសំដែងអំពីសង្គហធម៌ ដែលជាធម៌សម្រាប់សង្គ្រោះដល់គ្នានឹងគ្នា ដូចតទៅនេះ :—

កិច្ចឧបាយដែលសម្រាប់សង្គ្រោះ ឬស្រោចស្រង់គ្នានឹងគ្នាឲ្យបានមូលមិត្រ ហៅថា សង្គហៈ ។ នេះចែកចេញជា ៤ យ៉ាង គឺ :

១ — ទានៈ = ការចែករំលែកឲ្យ,

២ — បេយ្យវជ្ជៈ = ការពោលពាក្យពីរោះគួរឲ្យជាប់ចិត្ត,

៣— អត្ថចរិយា = ការប្រព្រឹត្តិឲ្យជាប្រយោជន៍ដល់គ្នានឹងគ្នា,

៤ — សមានត្តតា = ភាពជាអ្នកតាំងខ្លួនឲ្យស្មោះចំពោះបុគ្គលផងគ្នា ។

សង្គហធម៌ទាំង ៤ នេះ តែងប្រមូលជនទាំងឡាយឲ្យមូលមិត្រគ្នាក្នុងសកលលោក ។ បើសង្គហធម៌នេះមិនមានហើយ សាមគ្គី គឺការព្រមព្រៀងមូលមិត្រគ្នា ក៏នឹងធ្លុះធ្លាយបែកបាក់ទៅពុំខាន ។ ព្រះពុទ្ធជាម្ចាស់ទ្រង់សរសើរសង្គហធម៌នេះ ថាជាកិច្ចយ៉ាងប្រសើរបំផុតក្នុងលោក ។

ឯការសង្គ្រោះនេះ ជាប្រវេណីរបស់បុគ្គលអ្នកស្ថិតនៅក្នុងទីជាបុព្វការី ដូចមាតាបិតាមានភារៈខាងសង្គ្រោះបុត្តទាសកម្មករ; ឥស្សរជនមានព្រះរាជាជាដើម មានភារៈខាងសង្គ្រោះដល់ប្រជារាស្ត្រ ។

ជនដែលបានធ្វើសេចក្តីសង្គ្រោះចំពោះរូបណាមួយហើយ ជននោះឈ្មោះថាជាបុព្វការី, ជនជាបុព្វការីនោះ ក៏គួរទទួលយកកិច្ចដែលគេត្រូវធ្វើមកវិញ ។ សូម្បីតែជនអ្នកតូចមិនគិតប្រយោជន៍ផ្ទាល់ខ្លួន ហើយមានចិត្តមេត្តាសង្គ្រោះដល់ញាតិឯទៀតៗ ក៏គង់មានអ្នកដទៃគេរាប់អានជួយលើកតំកើងឲ្យទៅកាន់ទីជាធំបាន ។ ព្រោះហេតុនោះបានជាព្រះពុទ្ធជាម្ចាស់ ទ្រង់មានបំណងនឹងនាំសត្វឲ្យបានសំរេចគុណសម្បត្តិ គឺការតាំងខ្លួនត្រង់ក្នុងធម៌ ទើបទ្រង់សំដែងនូវសង្គហៈឧបាយនេះទុកជាផ្លូវដូចន័យដែលបានពោលមកខាងដើម ។ សង្គហៈនោះ រួមចូលដោយសង្ខេបជា ៤ គឺ: ទានៈ, បេយ្យវជ្ជៈ, អត្ថចរិយា, សមានត្តា ដូច្នេះ ។

ទានៈ= ការឲ្យ នោះ ចែកចេញជា ២ យ៉ាង គឺឲ្យសំដៅចំពោះរូបបុគ្គលម្នាក់ៗ ហៅថា អសាធារណទាន ១, ឲ្យជាសាធារណ៍ទូទៅមិនសំដៅចំពោះរូបបុគ្គលម្នាក់ៗ ហៅថា សាធារណទាន ១ ។ មាតាបិតាឲ្យអាហារគ្រឿងប្រដាប់ស្លៀកពាក់ ដល់បុត្តធីតាក្នុងវេលាដែលនៅកំឡោះក្រមុំ ឬឲ្យទ្រព្យសម្បត្តិធ្វើជាដើមទុន ឲ្យទីឋានផ្ទះសំបែងក្នុងកាលដែលបុត្រធីតាចំរើនវ័យហើយ; ចៅហ្វាយនាយឲ្យភោគសម្បទ

ដល់ទាសកម្មករ; ញាតិមិត្រចែកចាយគ្រឿងប្រើប្រាស់និងភោជនាហារ ដល់គ្នីគ្នា ៗ បុត្រធីតាដែលមានផ្ទះសម្បែងហើយ បានជូនភោជនាហារគ្រឿងស្លៀកពាក់ដល់មាតាបិតាដែលចាស់ជរា, ទាសកម្មករធ្វើការងារឬជូនរបស់ដល់ចៅហ្វាយនាំយជាហេតុសំដែងសេចក្ដីចងមេត្រីទៅ រកចៅហ្វាយនាយ; យ៉ាងនេះហៅថា អសាធារណទាន គឺបូជាឬតបគុណចំពោះរូបបុគ្គលម្នាក់ៗ ៗ

ឥស្សរជន ឬអ្នកមានទ្រព្យសម្បត្តិ ជាអ្នកមានចិត្តផ្សាយមេត្តាអាណិតអាសូរប្រណីដល់មហាជន ហើយលះបង់សេចក្ដីកំណាញ់បរិច្ចាគទ្រព្យធ្លួលគេឲ្យលើកថ្នល់ ជីកព្រែក ធ្វើស្ពាន ដើម្បីជាផ្លូវគមនាគមន៍បានស្រួល, សង់សាលា ដាំដើមឈើ ជីកស្រះ ដើម្បីជាទីសំណាក់អាស្រ័យដល់មនុស្សអាគន្តុកៈ; តាំងបង្កើតឬទំនុកបម្រុងធ្វើផ្ទះពេទ្យជាទីព្យាបាលរោគសព្វយ៉ាង, តាំងបង្កើតឬទំនុកបម្រុងសាលាបង្រៀនជាទីឲ្យបំណេះវិជ្ជាដល់កុមារកុមារី ៗ យ៉ាងនេះហៅថាឲ្យឬសង្គ្រោះជាសាធារណៈមិនចំពោះរូបបុគ្គល ៗ ទានមានសភាពយ៉ាងនេះ អាចឲ្យសេចក្ដីសុខដ៏ធំទូលាយ ជាងឲ្យចំពោះរូបបុគ្គលម្នាក់ៗ ព្រោះពង្រីកមេត្តាចិត្តផ្សាយទៅក្នុងលោកទាំងមូល ៗ ការឲ្យដោយសេចក្ដីសង្គ្រោះឬដោយសេចក្ដីផ្សាយមេត្តាចិត្តយ៉ាងនេះ ចាត់ជាបារមី ១ ហៅថា ទានបារមី ៗ ទានបារមីនេះព្រះពុទ្ធជាម្ចាស់ · ធ្លាប់បានបំពេញបានសន្សំមកច្រើនជាតិ

តតគណនាឡើយ, លុះព្រះអង្គបានត្រាស់ហើយទ្រង់សំដែងនូវសង្គហ-ទាននេះថាជាកន្លែងប្រដំណើរនៃសេចក្ដីសុខក្នុងលោកនេះ នឹងលោកខាងមុខ ៗ ទាននេះជាសង្គហៈទី ១ ។

អ្នកឲ្យទាន បើគ្រាន់តែឲ្យប៉ុណ្ណោះមិនបានពោលពាក្យពីរោះគួរឲ្យចាប់ចិត្តផងទេ, វត្ថុដែលឲ្យនោះ បើទុកជាច្រើនយ៉ាងណាក៏ដោយចុះ ក៏ប្រាកដហាក់ដូចជាតិច, បើពោលពាក្យពីរោះគួរឲ្យស្រណោះចាប់ចិត្ត ក៏វត្ថុការដែលឲ្យនោះសូម្បីតិចតួចសោះ ក៏ប្រាកដហាក់ដូចជាច្រើន ព្រោះធ្វើឲ្យកើតសេចក្ដីស្រឡាញ់ពេញចិត្ត ធ្វើអ្នកដែលមានឧបការៈឲ្យជាទីរាប់អានក្រៃលែងឡើង ៗ ព្រោះហេតុនោះ បានជាព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ចាត់បេយ្យវជ្ជៈ ថាជាសង្គហៈទី ២ ។

**បេយ្យវជ្ជៈ** ប្រែថា "ពាក្យដែលពីរោះគួរពេញចិត្តគួរចាប់ចិត្ត" ចែកចេញជា ២ យ៉ាង គឺ **បិយវាចា** = បានខាងវាចាពីរោះទន់ផ្អែមធ្វើអ្នកនិយាយឲ្យជាទីស្រឡាញ់របស់អ្នកស្ដាប់ ១, **អត្ថសញ្ហិតា វាចា** = វាចាប្រកបដោយប្រយោជន៍ ១ ។

បិយវាចា អាចនឹងទាញចិត្តមនុស្សក្នុងលោកឲ្យស្រឡាញ់រាប់រកគ្នាបាន ដូចមាតាបិតាចរចានឹងបុត្រធីតាដោយពាក្យទន់ផ្អែម, ដូចហៅថា កូន ថា នាង ដូច្នេះជាដើម ពាក្យនេះគួរឲ្យចាប់ចិត្តដល់បុត្រធីតាពន់ពេក ធ្វើឲ្យកើតសេចក្ដីស្រឡាញ់ ៗ បុត្រធីតាដែលចេះនិយាយពាក្យពីរោះ

គួរឲ្យចាប់ចិត្ត, មាតាបិតាក៏ស្រឡាញ់ពេញចិត្ត ។ ជនជាតស្ប្រៈដែល ឈ្លាសក្នុងការបដិសន្ថារៈ ពោលពាក្យពក់ពាក់ប្រស្រ័យស្រួលដល់អ្នកតូចទូទៅគ្រប់ជាន់គ្រប់ថ្នាក់ រមែងធ្វើខ្លួនឲ្យជាទីស្រឡាញ់ពេញចិត្តរបស់មនុស្សទាំងឡាយ បេះនិយាយដឹកនាំអ្នកតូចឲ្យមានគំនិតធ្វើកិច្ចការដោយសេចក្ដីប្រឹងប្រែងហើយឲ្យសុចរិតបានផង ។ ភាពទន់ភ្លន់នេះឯង បើទុកជាមនុស្សនោះពីដើមមកធ្លាប់ទាស់ទែងខ្វែងគំនិតគ្នា ដល់ទៅមើលមុខគ្នាមិនត្រង់ក៏ដោយ កាលបើបានឮសំដីពិរោះញយៗ ក៏អាចនឹងស្រាយកំហឹងនោះបាន ។ ដូចពាក្យបូរាណលោកពោលថា "សំដីជាឯក លេខជាទោ" សំដីនេះលើកទុកជាទីមួយ ចំណេះវិជ្ជាទុកជាទីពីរ ។ អ្នកដែលមានចំណេះយ៉ាងណាក៏ដោយចុះ, ប៉ុន្តែបើពោលវាចាមិនជាទីគាប់ចិត្ត ជាវាចាគំរោះគំរើយមិនពេញចិត្តអ្នកស្ដាប់, អ្នកមានចំណេះក៏ទៅជាឥតមានគេរាប់រកទៅវិញ ។ ជនអ្នកខ្សត់ខ្សោយចំណេះវិជ្ជាសោះទេ ប៉ុន្តែបើមានវាចាពីរោះ បេះទន់លំទោនសុភាពរាបសាល្អគួរឲ្យពេញចិត្ត. គង់មានអ្នកដទៃគេរាប់រកគេជួយសង្គ្រោះគេបូជា ឬឲ្យរត្ននេះនោះពុំខាន ។ ទាំងនេះក៏ដោយសារតែវាចាពីរោះ ។ ប៉ុន្តែមនុស្សម្នាក់ៗ មិនត្រូវធ្វើខ្លួនឲ្យឥតចំណេះវិជ្ជាទេ. ត្រូវតែខំប្រឹងរៀនសូត្រវិជ្ជាផ្លូវលោកផ្លូវធម៌ជាដរាប ។

អត្ថសញ្ញិតា វាចា = វាចាប្រកបដោយប្រយោជន៍នោះ សេចក្ដីថា ជនអ្នកស្រឡាញ់សេចក្ដីសុខ - ចំរើន និយាយតែសំដីណាដែលប្រកប

ដោយប្រយោជន៍ ជាសំដីមានតម្លៃឲ្យអ្នកស្តាប់ចូលចិត្តចង់ស្តាប់, ហើយអ្នកស្តាប់នោះយកទៅធ្វើតាមប្រតិបត្តិតាមទៅ ក៏រមែងកើតផលកើតប្រយោជន៍ ។ សំដីយ៉ាងនេះ បាត់ជាសំដីបានការ ជាសំដីអ្នកប្រាជ្ញ ។

ព្រះបរមសាស្តា ទ្រង់ទេសនាដឹកនាំវេនេយ្យសត្វ ឲ្យឃើញដោយបញ្ញាថា យ៉ាងនេះជាធម៌ យ៉ាងនេះមិនមែនជាធម៌. ទ្រង់ពន្យល់ឲ្យលះអកុសលធម៌ចេញ ហើយឲ្យសមាទានយកកុសលធម៌វិញ ឲ្យអាចហានរីកពយកនូវកុសលធម៌នោះៗ ទ្រង់បណ្តុះសេចក្តីពប់អានរបស់មហាជនទាំងគ្រហស្ថទាំងបព្វជិតឲ្យមានកម្លាំងតាំងនៅអស់កាលដ៏យូរអង្វែង ។ ព្រះពុទ្ធសាសនា ដែលនឹងអាចតាំងនៅបានរហូតមកដល់សព្វថ្ងៃនេះ ក៏អាស្រ័យព្រះពុទ្ធវាចា ជាវាចាពិត ជាវាចាមានប្រយោជន៍ ។ វាចាមានប្រយោជន៍នេះ ជាសំដីកាត់ថ្លៃពុំបាន ។ ការពោលពាក្យពីរោះយ៉ាងនេះបាត់ជាសង្គហៈទី ២ ។

**អត្ថចរិយា** កិរិយាប្រព្រឹត្តិជាប្រយោជន៍ដល់គ្នានោះ អធិប្បាយថា បើប្រសិនជាឲ្យ ឬនិយាយពាក្យពីរោះ ជាគុណចាប់ចិត្តចងមេត្រីទុកបានយ៉ាងស្និទ្ធក៏ពិត, ប៉ុន្តែបើជាមនុស្សចេះតែមើលបំណាំគ្នាទៅវិញទៅមក មិនប្រព្រឹត្តប្រយោជន៍ដល់គ្នានឹងគ្នា គឺថាមិនជួយប្រយោជន៍ឲ្យ មិនប្រាប់ឧបាយឲ្យកើតប្រយោជន៍ឲ្យ គ្រាន់តែឲ្យរបស់ប្រើប្រាស់ និងនិយាយតាមការសម្រួលប៉ុណ្ណោះ ការជិតស្និទ្ធនោះ ក៏នឹងសាបរលាបទៅ

វិញបានដោយងាយ ៗ ព្រោះហេតុនោះ អត្ថចរិយា ការប្រព្រឹត្តជាប្រយោជន៍ដល់គ្នានឹងគ្នានេះ ក៏ជាគុណយ៉ាងសំខាន់អាចយឹតយោងគ្នាឲ្យទៅកាន់សេចក្តីសុខ – ចំរើនតវែងទៅបាន ៗ

ឯការយឹតយោងឲ្យប្រយោជន៍ដល់គ្នានឹងគ្នានោះ ដូចជាមាតាបិតាខ្វល់ខ្វាយធ្វើប្រយោជន៍ឲ្យបុត្រធីតា គឺខំស្វែងរកទ្រព្យសម្បត្តិ ចំណេះវិជ្ជាផ្តល់ឲ្យបុត្រធីតាតាមជាន់តាមថ្នាក់; ចំណែកបុត្រធីតាវិញ ក៏ជួយខ្វល់ខ្វាយក្នុងកិច្ចការរបស់មាតាបិតា គឺជាត្រូវចិញ្ចឹមលោកដោយការគបគុណ ៗ ឥស្សរជនជួយធុរៈដល់អ្នកដែលត្រូវការពឹងពាក់ព្យាបាលទំនុកបំរុងឲ្យមានកេរ្តិ៍ឈ្មោះយសស័ក្តិប្រាកដក្នុងទីប្រជុំជន, រមែងជាទីនិយមរាប់អានរបស់អ្នកពឹងពាក់, អ្នកដែលពឹងពាក់ទៀតសោត ក៏ត្រូវធ្វើកិច្ចការរបស់លោកឲ្យសម្រេចតាមទំនងដែលលោកប៉ុនប៉ង, ធ្វើខ្លួនឲ្យលោកជឿជាក់នឹងទុកចិត្តបាន ឲ្យលោកស្រឡាញ់រឹងរឹតតែខ្លាំងឡើង ៗ

មិត្តសំឡាញ់ ក៏ត្រូវជួយខ្វល់ខ្វាយកិច្ចធុរៈគ្នាទៅវិញទៅមកដោយកម្លាំងកាយខ្លះ ដោយកម្លាំងវាចាខ្លះ កម្លាំងគំនិតខ្លះ កម្លាំងទ្រព្យខ្លះឲ្យសមតាមទំនងពុទ្ធភាសិតថា អត្ថម្ហិ ជាតម្ហិ សុខា សហាយា "មិត្តសំឡាញ់ទាំងឡាយ, កាលបើធុរៈកើតឡើង, រមែងជួយនាំឲ្យបានសេចក្តីសុខ" ទើបមានមេត្រីចិត្តរាប់រកគ្នាយ៉ាងស្និទ្ធ ៗ សូម្បីញាតិក៏ដូចគ្នាត្រូវតែជួយធុរៈគ្នា តាមលំដាប់ញាតិ, មិនចាំបាច់ញាតិសាច់សាលោហិត

ជិតគ្នាទេ ឲ្យតែរួមជាតិជាមួយគ្នា ក៏ត្រូវតែជួយផ្តល់ប្រយោជន៍ឲ្យតាមសមគួរ, យ៉ាងនេះទើបរាប់រកគ្នាទៅពេលមុខបានស្រួលល្អ ។ ឯការដឹកនាំក្នុងផ្លូវធម៌ទៀតសោត ក៏ត្រូវបបួលគ្នាឲ្យបរិច្ចាគធនធានធ្វើកុសល ដើម្បីនឹងញ៉ាំងគ្នាឲ្យស្រុះស្រួលគំនិតក្នុងការបុណ្យនោះ ឲ្យចេះស្និទ្ធស្នាលគ្នាតទៅ ។ ដូចជនអ្នកមានសីលធម៌ល្អអាចដឹកនាំអ្នកឥតសទ្ធាឲ្យមានសទ្ធា, ឥតសីលឲ្យមានសីល, កំណាញ់ស្វិតស្វាញឲ្យមានចិត្តទូលាយបរិច្ចាគទ្រព្យធ្វើបុណ្យ, អ្នកល្ងង់ខ្លៅ ឲ្យមានប្រាជ្ញា ។ យ៉ាងនេះឈ្មោះថាប្រព្រឹត្តប្រយោជន៍ដល់គ្នានឹងគ្នា រាប់ថាជាសង្គហៈទី ៣ ។

**សមានតតា** ភាពជាអ្នកតាំងខ្លួនឲ្យស្មោះស្មើទៅរកបុគ្គលផងគ្នា នោះអធិប្បាយ. បុគ្គលសូម្បីគ្រាន់តែឲ្យ ឬនិយាយពាក្យពីរោះព្រមទាំងជួយខ្វល់ខ្វាយធ្វើប្រយោជន៍ ឬណែនាំប្រាប់ប្រយោជន៍ដល់គ្នានឹងគ្នាតែប៉ុណ្ណោះ, តែបើមិនចេះរៀបចំខ្លួនប្រាណឲ្យសមតាមអត្តភាព គឺមិនស្គាល់ធំ-តូច-ខ្ពស់-ទាប ជាអ្នកប្រកាន់មានះក្អេងក្អាង មើលងាយគេធ្វើឫកពាក្រអឺតក្រអោងយ៉ាងនេះទេ, សេចក្តីរាប់អានគ្នា ក៏នឹងសាបរលាបទៅវិញ ។ លុះតែអាស្រ័យនូវសេចក្តីស្មោះស្មើ ឲ្យសមតាមអត្តភាពខ្លួនផង ទើបសេចក្តីរាប់អាននោះនឹងមានកម្លាំងអាចតាំងនៅយូរអង្វែងទៅបាន ។

ជនអ្នកមានវ័យតិច សូម្បីវិសេសជាងដោយយសសក្តិ ដោយអំណាច ដោយភោគសម្បទ ដោយបរិវារប៉ុណ្ណា ក៏ត្រូវតាំងខ្លួនឲ្យសមតាមបែប

ភាពយសសក្តិជាដើមប៉ុណ្ណោះ គឺត្រូវតែគំនាប់គាប់គួរដល់ជនអ្នកមានវ័យចំរើនជាងខ្លួន, ពីដើមមកធ្លាប់រាប់អានយ៉ាងណា ខាងក្រោយមកក៏ត្រូវរាប់អានយ៉ាងនោះ ៗ ជនទាំងឡាយដែលបានទទួលសេចក្តីគោរពកោតក្រែងយ៉ាងនេះហើយ ក៏រមែងស្រឡាញ់ពេញចិត្ត សំដែងអាការរាប់រកទៅវិញ ៗ

ពួកញាតិដែលមានវ័យស្មើៗគ្នាទៀតសោត ក៏ត្រូវសំដែងសេចក្តីរាប់អានគ្នាដោយពេញចិត្តចំពោះញាតិផងគ្នា, ទោះនិយាយស្តីក្តី ធ្វើការងារក្តី ដេក ដើរ ឈរ អង្គុយក្តី ក៏ត្រូវប្រព្រឹត្ត ត្រូវធ្វើ ត្រូវនិយាយស្តីឲ្យសមតាមអត្តភាពរបស់ខ្លួន ៗ ញាតិដែលជាអ្នកធំមានមេត្តារាប់អានញាតិដែលជាអ្នកតូច ស្និទ្ធស្នាលគ្នាទៅវិញទៅមក ជួយគ្នាទៅវិញទៅមក ដើម្បីគាំពារវង្សត្រកូលរបស់ខ្លួនឲ្យចំរើន; សេចក្តីសាមគ្គីនៃញាតិនេះ រមែងញុំាងសេចក្តីសុខឲ្យកើតមានទូទៅសព្វគ្នា; ដូចមានពុទ្ធភាសិតថា ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ "អ្នកប្រាជ្ញដែលមានមនុស្សមកនៅរួមជាមួយហើយ រមែងញុំាងសុខឲ្យកើត ដូចជាការជួបជុំនៃពួកញាតិដូច្នោះដែរ" ៗ

មួយទៀតជនដែលអាស្រ័យនៅក្នុងគណៈ ដូចជាភិក្ខុសង្ឃដែលអាស្រ័យនៅជាមួយគ្នាបាន ក៏ដោយអំណាចមានធម៌ស្មើគ្នា ៗ បើមិនដូច្នោះទេ ក៏មិនអាចនឹងរក្សាសាមគ្គីឲ្យគង់នៅបានឡើយ ៗ ព្រោះ

ហេតុនោះ បានជាលោកដែលជាប្រធាននៃគណៈ ត្រូវបំភ្លឺដើម្បីឲ្យមនុស្សទាំងឡាយក្នុងគណៈ និយមធ្វើតាមសណ្តាប់ធ្នាប់របស់គណៈ កំចាត់បង់នូវមនុស្សដែលល្មើសចេញ ហើយរក្សាសាមគ្គីរបស់គណៈឲ្យតាំងនៅមាំមួនឡើង ។

សមានត្តតានេះ បើធ្វើឲ្យសមដល់ហេតុផលរបស់បុគ្គល ឬគណៈ ហើយ រមែងយឹតយោងបុគ្គលនិងគណៈនោះ ឲ្យតាំងនៅក្នុងសាមគ្គីធម៌យ៉ាងជិតស្និទ្ធបាន ។ នេះចាត់ជាសង្គហទី ៤ ។ សំដែងមកក្នុងសង្គហធម៌ទាំង ៤ ចប់តែប៉ុណ្ណោះ ។

កាលបើចប់ធម៌ទេសនាហើយ សូមផ្សាយចំណែកកុសល ដល់អស់លោក-អ្នកទាំងឡាយ ដែលស្ថិតនៅក្នុងកម្ពុជរដ្ឋទាំងមូល សូមឲ្យបានសេចក្តីសុខចំរើនតរៀងទៅ ! ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

សព្វសត្វទាំងឡាយដែលដល់ហើយនូវសេចក្តីទុក្ខ ក៏ឲ្យបាត់ទុក្ខទៅ ! ដែលដល់នូវភ័យ ក៏ឲ្យបាត់ភ័យទៅ ! ដែលដល់នូវសេចក្តីសោក ក៏ឲ្យបាត់សោកទៅ ! (ដោយអំណាចធម្មទេសនានេះ) ។

សារលិខិត

# លោកស្វាមី វិវេកានន្ទ

**Message de SwamiVivekananda**

ដកស្រង់ពីទស្សនាវដ្តី ហ្វ្រង់អាស៊ី ថ្ងៃ ១៥ វិច្ឆិកា ១៩៤៦

## លោកប៉ាយ-ប៊ុកក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

---

ឱអ្នក! ជាទេពនិមិត្តនៅលើប្រថពី, អ្នកទទួលនូវបាបអកុសល, បាបនេះហើយដែលគេសន្មតហៅសភាពនៃមនុស្ស គឺជាទណ្ឌកម្មដែលធម្មជាតិមនុស្សត្រូវតែទទួល ; ក្រោកឡើងអ្នក, ឱអ្នកដែលជាពូជសត្វសិង្ហ! ត្រូវអ្នកលះបោលនូវការចាប់អារម្មណ៍ថាជាពួកចៀមនោះចេញឲ្យស្រឡះ, អ្នកជាមនោធម៌ប្រកបដោយអមត្តភាព ជាមនោធម៌មានសេរីភាពវិសេស ហើយមានលក្ខណៈជាអនន្តកាល (éternel); អ្នកមិនមែនជាវត្ថុធាតុឬរូបធាតុទេ ។ ឯវត្ថុធាតុត្រូវនៅក្រោមបង្គាប់បញ្ជាអ្នក មិនមែនអ្នកត្រូវបំរើវត្ថុធាតុនោះទេ ។

បើអ្នកមានអចលនសទ្ធាចំពោះអាទិទេពទាំង ៣៣០ លានអង្គដែលមានពណ៌នាក្នុងលទ្ធិបុរាណនិងអាទិទេពឯទៀត ដែលបរជាតិបានបញ្ចូលមកក្នុងប្រទេសអ្នក, ហើយអ្នកគ្មានសទ្ធាចំពោះខ្លួនអ្នក, អ្នកមិនអាចរកផ្លូវស្រោចស្រង់ខ្លួនអ្នកបានឡើយ ។ ឲ្យអ្នកមានចិត្តសទ្ធាមុនមាំចំពោះខ្លួនអ្នក ហើយអ្នកឈរឲ្យស៊ប់ត្រង់ពីលើសទ្ធានោះ ។

ប្រវត្តិសាស្ត្រសាកលលោក គឺប្រវត្តិសាស្ត្រនៃបុគ្គលណាដែលមានសទ្ធាចំពោះខ្លួនដោយខ្លួនឯង ។ គឺចិត្តសទ្ធានោះឯងដែលអាចញុំាងពលភាពនៃអាទិទេវគតិ (Divinité) ឲ្យកើតឡើងចំពោះអ្នក ។ ដោយការអប់រំនេះ បានជាអ្នកធ្វើការអ្វី ។ បានសម្រេចដូចបំណងទាំងអស់ ។ អ្នកដែលបរាជ័យក្នុងកិច្ចការទាំងនោះ ព្រោះតែអ្នកមិនបានព្យាយាមបញ្ចេញឲ្យគ្រប់គ្រាន់បរិបូណ៌នូវពលភាពខាងក្នុង ដែលមានមហិទ្ធិឫទ្ធិអស្ចារ្យ ។ បើកាលណាមនុស្សម្នាក់ ។ ឬប្រជាជាតិនីមួយ ។ លែងមានសទ្ធាចំពោះខ្លួន មនុស្សឬប្រជាជាតិនោះ។ ត្រូវទទួលមរណភាពក្នុងពេលនោះ ។ ព្រោះហេតុដូចនេះ ត្រូវជឿជាក់ចំពោះខ្លួនសិន រួចសឹមជឿអាទិទេព (Dieu) ជាខាងក្រោយ ។

អ្នកណាគ្មានជឿជាក់ចំពោះខ្លួនដោយខ្លួនឯង គេទុកអ្នកនោះជាពួកមិច្ឆាទិដ្ឋិ (Athée) ។ សាសនាពីបូរាណកាលមក ពោលថា អ្នកណាមិនជឿអាទិទេព អ្នកនោះជាមិច្ឆាទិដ្ឋិ ។ សាសនាសម័យថ្មី ពោលថា ពួកមិច្ឆាទិដ្ឋិ គឺបុគ្គលមិនមានជំនឿចំពោះខ្លួន ។

សំឡេងទ្វីបអាស៊ី ជាសំឡេងសាសនា, សំឡេងទ្វីបអឺរ៉ុប ជាសំឡេងនយោបាយ ។

ប្រទេសឥណ្ឌានឹងស្ថិតនៅក្នុងអមតភាពបាន លុះត្រាតែប្រទេសនេះនៅតែព្យាយាមស្វែងរកអាទិទេពតទៅអនាគត ។

ខ្ញុំមិនចង់ពោលថា ការពិសោធន៍ខាងផ្លូវនយោបាយ និងសង្គម មិនជាការខានពុំបាន; តែដែលខ្ញុំយល់ចំពោះបញ្ហានេះ ហើយដែលខ្ញុំមានប្រាថ្នាចង់ឲ្យចិត្តអ្នកជ្រាបច្បាស់នូវរឿងខាងលើ គឺថាចំពោះបញ្ហានេះ ត្រូវចាត់មកត្រឹមថ្នាក់ទីពីរ, ចំណែកខាងសាសនាជាវត្ថុសំខាន់បំផុត ត្រូវរាប់ជាថ្នាក់ទីមួយ ។

គ្មានបុគ្គលណានឹងអាចទប់ទល់នូវប្រទេសឥណ្ឌាបានឡើយ; ប្រទេសនេះនឹងលែងនិទ្រាលក់ទៀតហើយ; មិនមានបរជាតិមហាអំណាចណាមួយ អាចមានពលភាពធ្វើឲ្យប្រទេសនេះទន់ខ្សោយថយទៅក្រោយវិញបាន ព្រោះយក្សបានក្រោកឈរជាន់ជើងស៊ប់នៅលើផែនដីហើយ ។

បើអ្នកស្វែងរកសង្គហធម៌ចំពោះអ្នក នឹងទៅស្ថាននរក ។ អ្នកត្រូវស្វែងរកសង្គហធម៌ចំពោះបុគ្គលដទៃ ហើយបើទោះបីអ្នកធ្វើការប្រយោជន៍សាធារណៈ, អ្នកត្រូវទៅស្ថាននរក, ក៏អ្នកបានផលប្រយោជន៍ច្រើនជាងទៅស្ថានសួគ៌ ដោយការស្វែងរកសេចក្តីសង្គ្រោះចំពោះខ្លួន ។

ដរាបណាជនជាតិមនុស្សទាំងលាននាក់ នឹងត្រូវទទួលអនិច្ចកម្ម ដោយទុព្ភិក្ខភ័យនិងអវិជ្ជា, ដរាបនោះ ខ្ញុំទុកមនុស្សម្នាក់ៗ ជាអ្នកក្បត់ បើអ្នកនោះត្រូវការចិញ្ចឹមជីវិតដោយប្រស្រ័យគ្នានឹងមនុស្សទាំងនោះ ធ្វើចិត្តព្រងើយកន្តើយមិនរវល់គិតរឿងនេះ ។

ដកបណាសុខទៅប្រទេសខ្ញុំអត់ឃ្លានគ្មានអាហារនឹងបរិភោគ, ដកបនោះសាសនាខ្ញុំទូន្មានខ្ញុំថា ត្រូវតែចិញ្ចឹមខ្លួនសុខនោះ ។

តើអ្នកត្រូវទៅទីណា ដើម្បីនឹងស្វែងរកអាទិទេពឲ្យឃើញ? មិនមែនអាទិទេពទេឬ ពួកទុគ៌ត: (ខ្សត់ទ្រព្យ), វេទនាប្រាប្ត (រហេម-រហាម), ទុរពល (ខ្សោយ)? ការបឋមហេតុដូចម្ដេចបានជាមិនទៅបន់ឲ្យជួយពួកទាំងនោះហ្ន:? ហេតុដូចម្ដេចបានជាទៅជីកអណ្ដូងនៅមាត់ទន្លេគង្គា (Ganga) វិញ? ត្រូវអ្នកទុកពួកទាំងប៉ុន្មាននោះជាអាទិទេពរបស់អ្នក,(១) ផ្ចង់ចិត្តគិតទៅអ្នកទាំងនោះ ធ្វើការប្រយោជន៍អ្នកទាំងនោះ បន់គ្រប់ទីកន្លែងត្រូវឲ្យឧបត្ថម្ភអ្នកទាំងនោះ អាទិទេពមុខជានឹងបង្ហាញផ្លូវអ្នកមិនខាន ។

សាសនាស្ថិតនៅជិតសច្ចធម៌នៃបរលោក ដូចជាវិទ្យាសាស្ត្រខាងធាតុនិយម (chimie) និងខាងធម្មជាតិនិយម (Sciences Naturelles) ឯទៀតស្ថិតនៅជិតសច្ចធម៌នៃលោកបច្ចុប្បន្ន ។

បើប្រសិនជាអ្នកនឹងដកយកសាសនាចេញពីសង្គមមនុស្សជាតិ តើអ្នកនឹងឃើញនៅសល់អ្វីតទៅទៀត? នៅសល់តែមនុស្សពាលសាមាន្យ

---

១ កុំឲ្យយល់ថា: "អ្នក" ជាបុរិសគុណនាម ជាចំអហង្ការនោះឡើយ តែត្រូវយល់តាមអត្ថជាពិសេសថា: មនុស្សទាំងអស់ ចំពោះបុគ្គលនីមួយ ៗ ជាអង្គាកាត់នៃមួយចំហៀងអាទិទេពដែលស្ថិតខាងក្នុង (Une parcelle de la divinité) ហើយត្រូវជួយឧបត្ថម្ភអ្នកទាំងនោះ ទើបទៅដល់អាទិទេពបាន ។ កំណត់អ្នកបកប្រែ ។

(តំរួបានមនុស្ស) សេចក្ដីត្រេកត្រអាលក្នុងកាមគុណ មិនមែនជាវត្ថុបំណងរបស់អារ្យធម៌នៃមនុស្សជាតិទេ គឺគតិបណ្ឌិត (ជាន់ប្រាជ្ញា) ជាវត្ថុបំណងនៃជីវភាពទាំងអស់ ។

វត្ថុបំណងសំខាន់នៃមនុស្សទាំងអស់, បឋមបទនិងអវសានបទនៃសាសនាទាំងអស់វេញប្រមូលចូលទៅតែទ័យមួយបែប គឺឯកភាពមូលចូលទៅនឹងអាទិទេពឬប្រមូលចូលទៅក្នុងអាទិទេវគតិ ដែលស្ថិតនៅក្នុងធម្មជាតិប្រកបដោយសច្ចធម៌នៃមនុស្សនីមួយ ៗ ដែលមានលក្ខណៈដូចគ្នាខាងលើ ។

បើតាមពិត តើសាសនាអាចបំពេញនូវទិដ្ឋកម្មបានឬ? សាសនាអាចធ្វើកិច្ចការទាំងនេះបាន ។ សាសនានេះតែងនាំមកប្រគល់ឲ្យមនុស្សជាតិនូវជីវភាពជាទ័យកាល ។ គឺសាសនានេះឯងដែលរៀនមនុស្សឲ្យមានស្ថានភាព, លក្ខណៈ ដូចសម័យបច្ចុប្បន្ន ហើយធ្វើមនុស្សឲ្យប្រែទៅជាអាទិទេពក្នុងកាលជាអនាគត ។ នេះជាកិច្ចដ៏ប្រសើរដែលសាសនាអាចបំពេញបាន ។

ឧត្តមគតិនៃសាសនាទាំងគណៈទាំងអស់ គឺមូលចូលទៅក្នុងឧត្តមគតិតែមួយ ប្រាថ្នានឹងទៅកាន់សេរីភាព ព្រមទាំងចាកចេញពីសេចក្ដីទុក្ខ ។

ខ្ញុំប្រកាសថា មិនចាំបាច់ទៅបំផ្លាញសាសនា ដើម្បីនឹងឲ្យសម្រេចនូវសុភផលខាងសង្គមហិណ្ឌូនោះទេ ហើយថាសភាវៈនៃសង្គមនោះអាច

ស្ថិតស្ថេរនៅបាន ដោយប្រាសចាកសេចក្ដីបៀតបៀនដល់សាសនា ។ រឿងនេះគឺមកពីមិនបានយកសាសនាទៅអនុវត្តន៍ក្នុងសង្គម តាមសភាពដែលគួរការ ។

ក្នុងប្រទេសនីមួយៗ បើមានបុគ្គលដែលមានបដិភានុភាពដូចសត្វសីហៈ តែដប់ពីរនាក់ (គឺសត្វសីហៈ ដែលបានកាច់បំបាក់នូវច្រវាក់ខ្លួនបាន, យល់ឃើញច្បាស់ប្រាកដដោយបញ្ញាចក្ខុនូវអនន្តមាត្រ (Infini) ដែលអាត្មន៍បានធ្វើដំណើរទៅដល់ព្រហ្មន៍ (Brahman), ហើយខ្ជាក់ចោលស្រឡះពីសន្ដាននូវគ្រឿងអាមិសនឹងអំណាចព្រមទាំងកិត្តិយស) ពិភពលោកនឹងរំជួលខ្លាំង ។

បើតាមពិត, ឧត្ដមគតិរបស់ខ្ញុំគឺគ្រាន់តែយកពាក្យពីរបីម៉ាត់ មកពន្យល់ក៏អាចធ្វើបានដូច្នេះ : ទេសនាចំពោះមនុស្សជាតិក្នុងលោក សន្និវាសអំពីភាពអាទិទេព ដែលស្ថិតនៅក្នុងខ្លួនគ្រប់ៗគ្នា, ហើយបង្ហាញនូវមធ្យោបាយ ដែលអាទិទេពនោះធ្វើបាតុកិច្ចឲ្យច្បាស់លាស់ក្នុងការចលនានៃជីវភាពនីមួយៗ ។

អ្នកណាទាំងអស់ ដែលធ្វើពលិកម្មខ្លួនដោយខ្លួនឯងចំពោះព្រះអង្គ, អ្នកអស់ទាំងនោះ អាចធ្វើប្រយោជន៍ឲ្យពិភពលោកនេះបានច្រើនជាងអ្នកដែលធ្វើបុកភាពតាំងជាអ្នកបំរើព្រះអង្គត្រឹមតែសំដីពោលប៉ុណ្ណោះ ។

(មានត)

ការបណ្ដុះនិស្ស័យ

# ព្រះមហាឧត្តមវិជ្ជា ផលញាណោ ប៊ុង-ប៉ម

*អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង*

## ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ ពិនិត្យកែ

(តមក)

---

### ឧបាយបណ្ដុះនិស្ស័យទី ១

## និស្ស័យជាអ្នកល្អ

*អស់លោកប្រុសស្រីទាំងឡាយ! មនុស្សល្អគឺនរណា? បើលោកអ្នកចូលចិត្តថាមនុស្សល្អ គឺអ្នកមានទ្រព្យ, មានយសសក្តិ នឹងមានត្រកូលខ្ពស់ហើយ ក៏មុខជាមានគេជំទាស់បាន ។ ព្រោះមនុស្សទាល់ក្រ, មនុស្សគ្មានយសសក្តិនឹងមនុស្សត្រកូលទាប ជាមនុស្សល្អក៏មានដែរ ។ មនុស្សស្ដុកស្ដម្ភមាំមួន មានយសសក្តិ នឹងមនុស្សត្រកូលខ្ពស់ តែជាមនុស្សអាក្រក់ក៏មានដែរ ។*

*បើតាមពិត នរណាក៏ដោយ ឲ្យតែជាមនុស្សមានសេចក្តីល្អដំកល់ខ្លួននៅក្នុងធម៌របស់អ្នកល្អ, ប្រព្រឹត្តតាមធម៌ដែលជាសម្បត្តិរបស់អ្នកល្អហើយ ក៏ចាត់ជាមនុស្សល្អបានទាំងអស់ ព្រោះអ្នកល្អនោះតែងតែប្រព្រឹត្តល្អត្រឹមត្រូវដោយត្រៃទ្វារ ទាំងប្រកបដោយសិល្បវិទ្យាការជាគ្រឿងថ្លៃឲ្យទៅជាមនុស្សល្អ ។ កាលបើមិនមានសេចក្តីល្អជាសម្បត្តិនៅ*

ក្នុងខ្លួនហើយ សូម្បីជាមនុស្សរូបល្អ កើតក្នុងត្រកូលមហាសាល ឬជាមនុស្សជាន់ណាក៏ដោយ ក៏ជាមនុស្សល្អមិនកើត ហើយមិនជាទីស្រឡាញ់របស់អ្នកប្រាជ្ញផង មិនខុសគ្នាអំពីផ្កាបាឡើយ ព្រោះផ្កាបាមានតែពណ៌ល្អប៉ុណ្ណោះ ឥតក្លិនទេ ទើបមិនជាទីនិយមរីករាយរបស់មនុស្សខ្លូទៅ ។

សូមចាំកុំភ្លេចថា មិនមែនផ្កាឈើ មិនមែនពេជ្រនិលចិន្តាមណី មិនមែនអាភរណៈដែលថ្លៃថ្លា មិនមែនគ្រឿងប្រដាប់យ៉ាងដទៃៗទេ ដែលសម្រាប់ធ្វើឲ្យយើងល្អនោះ, សម្បត្តិរបស់អ្នកល្អផ្សេងៗ ដោយឡែកទៀត ។ ប្រសិនបើយើងធ្វើខ្លួនយើងឲ្យជាមនុស្សល្អមែនៗ យើងត្រូវតែមានសម្បត្តិមនុស្សល្អ ។ សម្បត្តិមនុស្សល្អរមែងជាសិរីនៃត្រកូល ដូចទង់ជ័យជាគ្រឿងសំគាល់នៃជ័យជំនះដូច្នោះ ។ ស្ត្រីមានស្វាមីដែលសម្បូរដោយសម្បត្តិជាមនុស្សល្អ រមែងមានអំណាចលើសនឹងលើសព្រះសុរិយាដែលភ្លឺរុងរឿងក្នុងអាកាសវេហាស៍, សូម្បីបុរសមានភរិយាដ៏ប្រកបព្រមដោយសម្បត្តិជាអ្នកល្អ ក៏ជាអ្នកហ៊ីហានឹងត្រជាក់ត្រជំដូចជាពន្លឺនៃនិសាករក្នុងរាត្រីកាល ។

មនុស្សថោកទាប មនុស្សគ្មានយសស័ក្តិនឹងមនុស្សត្រកូលទាបដែលមាននិស្ស័យជាអ្នកល្អ ប្រសើរជាងមនុស្សស្ដុកស្ដម្ភ មនុស្សមានយសស័ក្តិនឹងមនុស្សត្រកូលខ្ពស់ ដែលមាននិស្ស័យថោកទាបនោះទៅទៀត ។

ពិតមែន យើងតែងនិយមហានៈជាអ្នកស្តុកស្តម្ភ ទាំងកប់អានយសសក្តិ ព្រមទាំងបូជាត្រកូលខ្ពស់ ព្រោះរបស់អម្បាលនេះ អាចឲ្យគុណប្រយោជន៍ដល់កៀនកក្ដិផងគ្នាជាច្រើន តែបើម្ចាស់របស់ជាមនុស្សមាននិស្ស័យថោកទាបហើយ សូម្បីមានទ្រព្យច្រើន រុងរឿងដោយយសសក្តិ កើតក្នុងត្រកូលខ្ពស់ក៏ដោយ ក៏ឥតបានជាប្រយោជន៍ដល់ខ្លួននិងអ្នកដទៃដែរ មិនតែប៉ុណ្ណោះត្រឡប់ទៅជាឲ្យទោសដល់ខ្លួនថែមទៀតផង ។

ភាពល្អរបស់អ្នកល្អ នៅត្រង់ការកាន់ធម៌ជាគោលចារឹក មានគុណធម៌នៅក្នុងចិត្តពិតៗ កើតអំពីខ្លួនឯងមិនមែនកើតអំពីសម្បត្តិទ្រព្យ ជាតិត្រកូលណាមួយឡើយ ។ អ្នកល្អតែងប្រព្រឹត្តធ្វើតាមសភាវៈពិត និងសភាវៈល្អ មិនប្រព្រឹត្តតាមគាប់ចិត្តរបស់ខ្លួន ឬតាមនិយមរបស់លោក ឬក៏ដោយបុទ្ធិនៃលោក ក្រោធវង្វេងទេ, បើនឹងប្រកបកិច្ចការគ្រប់យ៉ាង តែងចង់ត្រួតត្រាឲ្យឃើញខុសត្រូវអាក្រក់ល្អជាមុន តែដើម្បីឲ្យត្រឹមត្រូវតាមលទ្ធិទំនៀមទំលាប់ប្រវេណីមាត្រាច្បាប់ និងបែបផែនដែលលោកនិយមសូម្បីឃើញខុសត្រូវអាក្រក់ល្អខ្លួនឯង ក៏ត្រូវត្រួតត្រាប្រឡងឲ្យល្អិតតទៅទៀត, មិនតែប៉ុណ្ណោះឡើយ កាលប្រាថ្នានឹងឲ្យត្រឹមត្រូវតាមផ្លូវធម៌ បើទុកជាឃើញត្រឹមត្រូវតាមផ្លូវលោកនិយមហើយក៏ដោយ ក៏ត្រូវពិនិត្យពិចារណាឲ្យហ្មត់ចត់ក្នុងផ្លូវខុសត្រូវអាក្រក់ល្អ ដោយពិនិត្យពិច័យទៀត, ទាំងនេះមកពីអ្នកល្អបេះបង្វែរខ្លួនឯងឲ្យសមគួរដល់លោក

នឹងធម៌ មិនស្រវឹងទាញលោកឲ្យក័ន្តវៃប្រមកសម្រាប់ឋានៈរបស់ខ្លួនឡើយ ត្រូវនឹងគតិថា "ការប្រព្រឹត្តឲ្យត្រឹមត្រូវតាមលោកនិយម គ្រាន់បើជាង ការធ្វើតាមអំណាចចិត្តឯង ឯការប្រព្រឹត្តឲ្យត្រឹមត្រូវតាមផ្លូវធម៌ រឹងរឹតតែប្រសើរជាងការធ្វើឲ្យត្រូវតាមផ្លូវលោកនិយមតទៅទៀត" ។

និស្ស័យជាអ្នកល្អ រាប់ថាជាកិត្តិយសខ្ពង់ខ្ពស់បំផុត, ដែលអ្នកមានចិត្តជាធម៌ តែងនិយមរាប់អានមិនចេះធ្វែត ។ អ្នកដែលមានយសសក្តិខ្ពស់ឬមនុស្សដែលរើសូស មិនបង្អោនខ្លួនគោរពអ្នកមានបុណ្ណាសក្តិ ក៏ត្រូវតែគួរគោរពចំពោះអ្នកល្អដែរ ទោះបីអ្នកនោះមិនមានយសសក្តិ ឬមានយសសក្តិទាបជាងក៏ដោយ, ព្រោះមនុស្សដែលគួរស្រឡាញ់ គួរគោរព គួររាប់អាននោះ មិនមែនដោយសារតែអ្នកនោះមានត្រកូលឬមានយសសក្តិខ្ពង់ខ្ពស់ ឬក៏ទៅជាកំឡោះ ក្រមុំ មានអាយុច្រើនជាងឡើយ តាមពិត គឺដោយសារតែអ្នកនោះ មានសម្បត្តិអ្នកល្អនៅកងខ្លួន ជាគ្រឿងលើកដំកើង ឲ្យទៅជាមនុស្សគួរស្រឡាញ់គួរគោរព គួររាប់អានប៉ុណ្ណោះ ។ ម្យ៉ាងទៀត សូម្បីទ្រព្យសម្បត្តិនឹងត្រកូលដំម្កាមួន ដែលមាតាបិតាតាំងចិត្តកសាងឡើងដើម្បីទុកឲ្យកូនចៅក៏ដោយ បើកូនចៅជាមនុស្សមាននិស្ស័យអាក្រក់ ក៏រក្សាទុកមិនបានដែរ លុះតែកូនចៅមាននិស្ស័យជាអ្នកល្អផង ទើបអាចថែរក្សាទុកបាន មិនតែប៉ុណ្ណោះ សូម្បីមាតាបិតាមិនបានធ្វើទុកឲ្យ ក៏អ្នកល្អអាចតាំងខ្លួនឲ្យជាមនុស្សឧត្តុង្គឧត្តមសម្បូរឡើងឯងៗ បានដែរ ។

មនុស្សគ្រប់គ្នា សុទ្ធតែចង់បានភាពជាមនុស្សល្អទាំងអស់ ហើយក្នុងម្នាក់ៗ សុទ្ធតែព្យាយាមសំដែងអាការកិរិយាលំនាំឲ្យទៅជាមនុស្សល្អគ្រប់វិធី ៗ តែមនុស្សខ្លះវង្វេងបួលចិត្តខុសថា "ការចរចា ឬ ធ្វើលំនាំឫកពាខ្លួនឲ្យអ្នកដទៃឃើញថាខ្លួនជាអ្នកធំ ជាមនុស្សគ្រាន់បើនោះ ជាការសមគួរដល់កិរិយារបស់អ្នកល្អ" ៗ កាលបើគេប្រព្រឹត្តកិរិយាតាមដែលគេយល់ឃើញខុសយ៉ាងនេះហើយ ក៏នឹកសង្ឃឹមថាមានគេសរសើរខ្លួនថាជាអ្នកល្អឡើយ មុខជាត្រឡប់ត្រូវពាក្យដំនៀលថាជា "មនុស្សព្រៃ ខំត្រដរធ្វើឫកពាសង្ហាឲ្យគេថាខ្លួនជាអ្នកធំ អ្នកជាន់ខ្ពស់ ហួសប្រមាណ" ដូច្នេះពុំខាន ៗ ពិតមែនអាកប្បកិរិយាដែលគួរគប់អានគួរឲ្យបូជារបស់ពួកមនុស្ស នៅត្រង់ការធ្វើឬការនិយាយចរចា ដោយមេត្តាចិត្តចំពោះអ្នកដទៃ ៗ ឯការធ្វើឬការនិយាយដែលប្រកបដោយមេត្តាចិត្តបែបនេះ រមែងបានទទួលផល គឺការសុភាពរាបសា ទុនលំទោន ទទួលអញ្ជើញការប្រស្រ័យសាកសួរ ដោយអធ្យាស្រ័យដ៏ប្រកបព្រមដោយមេត្តាចិត្ត ករុណាចិត្តនឹងចិត្តជាបុណ្យ ជាទីត្រជាក់ចិត្ត ចាប់ចិត្ត ចាប់ត្រចៀក អំពីសំណាក់មនុស្សដទៃទាំងមិនមានមនុស្សដទៃណាមួយស្អប់ខ្ពើម ឬគរហានិន្ទាឡើយ នេះឯងហើយជាអាកប្បកិរិយារបស់អ្នកល្អ ៗ

ជនណាមាន ជាតិវង្ស ពង្សថោកទាប
តែខំសាង អត្តភាព យ៉ាងខ្លាំងក្លា
មិនខ្លាចក្តៅ រងា ជាធម្មតា
ជននោះ កែអាត្មា ឲ្យខ្ពស់បាន ៗ
មនុស្សល្អ មានវង្ស ដ៏ស្តុកស្តម្ភ
តែភ្លើតភ្លើន មិនខំ តាំងខ្លួនប្រាណ
យូរៗទៅ ផៅពង្ស គង់សាមាន្យ
ធ្លាក់ទៅកាន់ ហីនដ្ឋាន ពុំខានអើយ ! ៗ

អ្នកល្អតែងមាននិស្ស័យល្អជាភូមិធម៌ អែបនែបនៅក្នុងសន្តាន មិនមែនសំដៅយកថាល្អ ដោយគ្រឿងតែងកាយឬទ្រព្យសម្បត្តិណាមួយឡើយ ៗ កាលអ្នកល្អ មាននិស្ស័យល្អជាក្រោះហុំខ្លួនហើយ សូម្បីតែងខ្លួនតែល្មមសុភាពរាបសា ហើយចុះទៅក្នុងប្រទេសណា ដែនណា ក៏អាចជាទីញ៉ាំងជនក្នុងប្រទេសនោះដែននោះ ឲ្យស្នេហានឹងមានការរាប់អានយ៉ាងក្រៃលែងចំពោះខ្លួនបានដែរ មិនចាំបាច់ស្រែកគេ ទីលំនៅនឹងសេចក្តីរុងរឿង ចំថ្កើងអំពីទីណាទេ ៗ យើងអាចកំណត់ដឹងនិស្ស័យល្អរបស់អ្នកល្អបាន ដោយអាស្រ័យការសង្កេតភូមិធម៌ដែលមាននៅប្រចាំក្នុងសន្តានរបស់អ្នកល្អនោះសូម្បីមានចំនួនប៉ុន្មាន ក៏នឹងប្រកាសឲ្យយើងដឹង - ឃើញបានចំនួនប៉ុណ្ណោះ តាមលំនាំនៃអាការ

កិរិយានិងវាចា ដែលអ្នកល្អសំដែងចេញមក, ដូចជាសំដែងកិរិយាមារយាទល្អ ចំពោះអ្នកតូច ឬអ្នកមានកំឡាំងអន់ជាង ឬក៏ប្រព្រឹត្តអាកប្ប-កិរិយានិងវាចាល្អ ចំពោះមនុស្សទូទៅជាដើម ព្រោះនិស្ស័យល្អដែលនឹងលេចចេញឡើងបាននោះ រមែងមានប្រាកដឡើងអំពីការប្រព្រឹត្តិតាមផ្លូវកាយផ្លូវវាចារបស់អ្នកល្អ គប្បីសង្កេតដូចតទៅនេះ :–

**១ – អ្នកល្អ តែងមានមារយាទល្អ. –** កិរិយាមារយាទដែលរឹងប៉ឹង ទន់ល្មោន ថ្លៃថ្នូរ បន្ទន់ខ្លួន អត់ធ្មត់ស្ងប់ស្ងៀម សុភាពរៀបរយ សំដែងសេចក្ដីករុណាប្រណី នឹងពេញពោរទៅដោយមេត្តាជាដើម នេះជាមារយាទល្អ ។ កិរិយាមារយាទដែលរឹងរូស រឹងត្អឹង ថោកទាបព្រោឡើសបើស ប្រជែងប្រជាង មិនពបសា អាក្រក់គ្រោតគ្រាត អួតខ្លួនជាដើម. នេះជាមារយាទអាក្រក់ ។

អ្នកដែលមានមារយាទល្អ តែងមានឫកពា និងវាចាខែងរែងមិនមែនប្រជែងប្រជាង តែងទន់ល្មោន មិនមែនទនដោយអែបអបទេវាយដំឡៃរបស់ខ្លួនតែបន្តិចបន្តួច លើកខ្លួនអួតយសសក្ដិ អួតគុណវុឌ្ឍិ អួតសមត្ថភាពឲ្យហួសប្រមាណ សូម្បីនឹងធ្វើអ្វីត្រឹមតែបន្តិចបន្តួច ក៏សមល្អគួរមើលគួរកោតយបាន ហើយការធ្វើនោះ ជាគ្រឿងលើកស្ទួយសេចក្ដីល្អឲ្យកណ្ដាតឡើងផង ដូចផ្កាំងមាសជាំពេជ្រអាចក្ដីព្រោងព្រាយឡើងបានដូច្នោះ ។ អ្នកមានមារយាទថោកទាប រមែងសង្កត់ខ្លួនឲ្យធ្លាក់ទៅ

ទីទាប, នឹងធ្វើអ្វី សូម្បីជាអង្គនៃសេចក្តីល្អ ក៏ធ្វើឲ្យជាទីស្អប់ត្រចៀក ទាស់ភ្នែក ផ្សាចិត្តរបស់អ្នកដែលបានមកឃើញ បើខំសំដែងចេញទៅត្រឹមណា ក៏រឹងរឹតតែជាទីទំនាស់ដល់អ្នកដទៃត្រឹមនោះ ។

បើយើងស្រឡាញ់មារយាទល្អ យើងត្រូវរក្សាមារយាទឲ្យមានបដិ-សណ្ឋារៈល្អ មានវាចាពីរោះ មានកិរិយាសមរម្យទន់លំទោនចំពោះអ្នកធំ ឬអ្នកដែលទាបតូចជាងខ្លួន, បើយើងមានបុណ្យសក្តិធំ ក៏រឹងរឹតតែត្រូវមានកិរិយាទន់លំទោនចំពោះមនុស្សទូទៅថែមទៀត ។ កុំសំដែងមារ-យាទៈថោកទាបក្នុងភូមិក្នុងអាពាម ក្នុងសង្គមនិងក្នុងសាធារណដ្ឋាន គឺទីដែលប្រាកដដល់សាធារណជន ។

ក) កុំប្រើអាកប្បកិរិយាថោកទាប ខ្ជិខ្ជា ល្ងង់ខ្លៅ ប្រងេងប្រងាង ប្រៀតប្រៀតគេឯង កុំបញ្ចេញអាការៈវៀសវៃទៅមក ចង្អុលទាយអាយ នឹងកុំប្រើកិរិយា ធ្វើមាត់បេញមុញ ។

ខ) កុំធ្វើសំឡេងឡូឡា នឹងកុំសើចហ៊ាកក្រញ្ជៀវដោយឥតហេតុ កុំប្រើវាចាសៀតស៊ិកប្លាមកអាក្រក់ កុំសំដែងកិរិយានិងវាចាគោសរូស ប៉ប៉ាច់ប៉ប៉ោចចំអកចំអន់អ្នកដទៃ កុំនិយាយគំហកគំហែន មើលងាយដៀលត្មះបាក់រុកឲ្យគេទាស់ទែងគ្នា ។

(មានត)

# សាវតារវត្តគោកនពរង្សី ហៅគោក

នៅឃុំរលួស ស្រុកសូទ្រនិគម ខេត្តសៀមរាប

## ព្រះមហា គុយ - ហួត

សិស្សសាលាបាលីជាន់ខ្ពស់ ភ្នំពេញ

រៀបរៀង

(រង្វាន់លេខ ៣)

វត្តគោកនពរង្សីនេះឋិតនៅក្នុងមណ្ឌលខេត្តសៀមរាប ក្នុងឃុំរលួស ស្រុកសូទ្រនិគម ឈៀងអគ្នេយ៍នៃខេត្តសៀមរាប ក្នុងកម្ពុជរដ្ឋ ។ អារាមនេះ កើតឡើងដោយគ្រហស្ថមានងារស័ក្តិ ជាចៅហ្វាយស្រុក និងបាឡាត់ស្រុក គេ២បុរសគឺបិតានិងបុត្ត ធ្វើរាជការក្នុងស្រុកសូទ្រនិគមនោះ បានផ្តើមកសាងមុនគេទាំងអស់ ។

អារាមនេះគេសាងឡើង ក្នុងរជ្ជព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី (ព្រះអង្គដួង), ឯសកពជមិនប្រាកដ ប៉ុន្តែក្នុងសម័យនោះខេត្តសៀមរាបនៅក្នុងអំណាចរាជការសៀមនៅឡើយទេ ។

បុព្វហេតុដែលនាំឲ្យកសាងវត្តនេះឡើងនោះ មានរឿងរ៉ាវជាគ្រឿងប្រារព្ធថា: នៅចំពីខាងកើតអារាមនេះ ចំនួន ៥០០ ម៉ែត្រ ពីទួលវត្តនេះទៅ មានទួលមួយមានដើមពោធិពីរដើមដុះលើទួលនោះ គេហៅថាទួលពោធិពីរ ។ សម័យមួយមានពួកក្មេងជាច្រើន បាននាំគ្នាទៅឃ្វាល

គោក្របី ក្បែរទួលពោធិពីរនោះកំពុងតែលេងឈូធរ រត់ចុះរត់ឡើង ស្រាប់តែបានឃើញពស់មួយលូនក្បែរទីនោះ ក៏នាំគ្នាដេញវាយពស់ ។ ឯពស់ក៏យក៏លូនយ៉ាងលឿនទៅចូលរន្ធដើមពោធិនោះ, ក្មេងទាំងអស់ក៏នាំគ្នាចាក់ម្នាងម្នាក់ទៅវិញទៅមក កំពុងតែចាក់ ក៏បានឃើញនាគថ្មមានសណ្ឋានបើកពពារ; ក៏នាំគ្នារត់ទៅប្រាប់ម្ដាយឪពុកចាស់ៗ ឯភូមិ ៗ អ្នកស្រុកក៏បាននាំគ្នាកាន់ចបជ្រែកជាដើមមកកាន់ទីនោះ ហើយក៏នាំគ្នាជីកកន្លែងនោះ, លុះជីកបន្តិចទៅ ក៏បានឃើញព្រះពុទ្ធរូបមួយអង្គ គង់លើខ្នងនាគ ពពារនាគបាំងពីលើ ព្រះហស្តទាំងពីរជំរួតលើគ្នាបែបចូលសមាធិ (ព្រះពុទ្ធរូបនេះប្រហែលជាគេកសាង តំណាងព្រះសម្ពុទ្ធដែលគង់ក្បែរមុចលិន្ទស្រះ) ព្រះពុទ្ធរូបនេះរចនាដោយសិលាម័យ ខាងក្រៅវិចិត្រដោយទឹកមាស (ព្រះពុទ្ធរូបបែបនេះហៅថាព្រះពុទ្ធនាគប្រក់) ។

មហាជនលុះបានឃើញព្រះពុទ្ធរូបនោះ ក៏មានចិត្តជ្រះថ្លា នាំគ្នាធ្វើបុណ្យយ៉ាងឧឡារិក រួចកដង្ហែទៅទួលមួយនៅចំពីខាងលិចទួលពោធិពីរនេះ គឺកន្លែងកសាងវត្តសព្វថ្ងៃនេះ ហៅថា "ទួលរកា" ព្រោះមានដើមរកាដុះពីលើ ។

នៅស្រុកសូទ្រនិគម ក្នុងសម័យនោះ មានចៅហ្វាយស្រុកម្នាក់ ឈ្មោះកែវ ព្រមទាំងកូនម្នាក់ ឈ្មោះណុប ធ្វើបាឡាត់ស្រុក ក្នុងស្រុកជាមួយគ្នា បានតាំងផ្ដើមជាមេនាំកសាងវត្តនេះ ជាដំបូងបំផុត ។

លុះសាងរួចហើយ ក៏ដាក់ឈ្មោះថា ក្រៃវណពរង្ស ដោយផ្សំឈ្មោះខ្លួន នឹងឈ្មោះកូន ជាអ្នកនាំសាងមុនគេនោះ ។

លុះចំណេរជាខាងក្រោយមក អ្នកស្រុកក៏នាំគ្នាហៅថា វត្តរកា ព្រោះទួលនោះមានដើមរកាមួយដើម ។ ឯពាក្យថា កៃវនពរង្ស ជានាមាភិធេយ្យដំបូង គ្មាននរណាហៅទេ សព្វថ្ងៃតែឈ្មោះថា វត្តរកាទៅវិញ ។

ឯព្រះពុទ្ធរូបនោះ គេបានដំកល់ទុកក្នុងវិហារ ជាបូជនិយដ្ឋានមកដល់សព្វថ្ងៃនេះ ។ វត្តនេះមិនសូវសម្បូណ៌សេនាសនៈទេ វិហារដែលកសាងពីមុនមកក៏បាក់ទ្រុឌទ្រោមអស់ ឥឡូវកំពុងកសាងម្តងទៀត ។

**រៀបរាប់អំពីផែនទីធ្វើវិហារ** – វិហារគេត្រូវជ្រើសរើសទីកន្លែងដីកបស្មើចាក់ដីបុកបុសដោយមធ្យត់ ហើយត្រូវលើកដីឲ្យខ្ពស់ជាងកន្លែងធ្វើសេនាសនៈទាំងពួង, លុះធ្វើស្ដារកិច្ចរួចហើយ ទើបធ្វើវិហារជាខាងក្រោយ ។ ចំណែកខាងវិហារដែលធ្វើបែរមុខទៅខាងកើតនោះ គឺធ្វើតាមប្រវេណីពីបុរាណមក ដោយគេអាងដល់គម្ពីរបណ្ណុលសារពេជ្ញ អ្នកប្រាជ្ញដែលតែងគម្ពីរនោះពន្យល់ថា “ ការដែលធ្វើវិហារបែរមុខទៅខាងកើតនោះទើបមានផលានិសង្សបរិបូរ ” ។ ម្យ៉ាងទៀត បោរាណាចារ្យខ្លះពោលថា ការធ្វើវិហារបែរមុខទៅទិសខាងកើតនេះ ដើម្បីគម្រប់ចំពោះព្រះសម្ពុទ្ធពេលព្រះអង្គបានត្រាស់ទ្រង់បែរព្រះភក្ត្រទៅទិសខាងកើត ។

**របៀបសាងកុដិសាលា** — កុដិនឹងសាលាគេត្រូវសង់ពីខាងលិចឬខាងជើងនៃវិហារ, នេះតាមគម្ពីរបណ្ណលសារពេជ្រដែរ ។ ឫក្សពារវេលាដែលត្រូវសាងវិហារនោះដូចតតមានប្រាកដទេ. ប៉ុន្តែទំនៀមនេះធ្លាប់មានខ្លះ គឺថាបើថ្ងៃដែលលើកវិហារត្រូវឲ្យលោកគ្រូចៅអធិការថយចេញពីវត្ត លួមមិនឲ្យឮស្គរសំឡេងគងរគាំង ដរាបដល់លើកវិហារហើយសិមត្រឡប់មកវិញ ។ ឯការណ៍ដែលកំណត់យ៉ាងនេះ ព្រោះគេប្រយ័ត្នកុំឲ្យលោកគ្រូចៅអធិការចាញ់អំណាចវិហារ កុំឲ្យមានគ្រោះថ្នាក់ក្នុងថ្ងៃក្រោយ ៗ .

ឯវត្តដែលចាប់រៀបចំថ្មី មិនទាន់សាងវិហារ គេត្រូវធ្វើរោងសម្រាប់ធ្វើឧបោសថសិន គេហៅថា "ប្រោត" ។ មុននឹងសាងវិហារគេយកឈើមានខ្លឹមទៅបោះធ្វើគោលចំណាំ ដល់ពេលក្រោយបានគេប្រជុំឧបាសកឧបាសិកាជើងវត្ត មានអាចារ្យសម្រាប់វត្តជាប្រធាន ពិនិត្យទីកន្លែងនឹងសាងវិហាររួច ទើបគេកំណត់ត្រង់កន្លែងណាមួយព្រមគ្នា ហើយចាប់សាងជាវិហារឡើង ។

មុននឹងសាងព្រះវិហារ, គេត្រូវជ្រើសរើសគ្រឿងវិហារុបករណ៍តាមចូលចិត្ត ឈើឬស៊ីម៉ង់តតាមធនធានរបស់អ្នកជើងវត្ត ។ មុននឹងលើកវិហារ មានរៀបពិធីសូត្រមន្តហើយមានខ្លះរៀបក្រុងពាលីផង, ព្រឹកឡើងបានលើកគ្រឿងវិហារដែលបានរៀបចំជាស្រេចមកហើយនោះ ។

ឯវត្តទាំងមូលគេត្រូវកត់ចំណាំតាមភាពតូច-ធំ ឬតាមប្រមាណដី ដែលគេបានវេរប្រគេនសង្ឃ ត្រឹមត្រូវតាមវិនយកម្ម ។

ឯសេនាសនៈដែលធ្វើក្នុងអារាមសាងថ្មីនោះឥតមានកំណត់ទេ តាមសទ្ធា និងភោគសម្បទ របស់ម្ចាស់កម្មសិការធ្វើវត្ត បើមានលុយសាងកុដិមាំទាំទៅក៏បាន បើគ្មានទេ គ្រាន់តែធ្វើរោងស្លឹកប្រគេនលោកគង់នៅបណ្ដោះអាសន្នសិនក៏បានដែរ ។

របៀបកសាងវិហារ ក្នុងពុទ្ធសាសនា សុទ្ធតែធ្វើផក់រូបនាគ, ហោជាងជារូបទេវតាកាន់ក្រាំង ឬសៀវភៅទាំងអស់ឥតមានប្លែកគ្នា, ឬមួយជារូបព្រះនារាយណ៍តាមគាប់ចិត្តស្រឡាញ់ (មតិរបស់អ្នកតែងរឿងនេះនិងមតិចាស់ៗ ពីជាន់ដើមខ្លះ) ។

មានសេចក្ដីអធិប្បាយថា ផក់ជារូបនាគព័ទ្ធពីខាងលើនោះ គឺបានសេចក្ដីថា នាគជាសត្វមានពិសនិងមានកម្លាំងច្រើន ឯព្រះពុទ្ធសាសនាទាំងមូលមានវិហារ ជាគោលចារិក, ហេតុនេះនាគគឺពុទ្ធបរិស័ទនេះគោងប្រឹងប្រែងផ្គុំកម្លាំងគ្នាឡើង ថែទាំការពារគោរពចំពោះសាសនាដោយពេញកម្លាំង ត្រូវព្រួសពិស គឺការប្រឹងផ្សាយពុទ្ធឱវាទរបស់ព្រះសម្ពុទ្ធ ឬក៏ខំប្រឹងកំចាត់បច្ចាមិត្ត ដែលប៉ងប្រទូស្តរាយចំពោះពុទ្ធសាសនាទាំងមូល ឲ្យវិនាសខ្ចាត់ចេញទៅ ដូចជារូបនាគដែលមានសណ្ឋានប្រឹងអើតកដោយពេញកម្លាំងនោះឯង (នាគនេះជាប្រស្នារបស់អ្នកប្រាជ្ញពីមុន នាគក្នុងទីនេះសំដៅដល់ពុទ្ធបរិស័ទទាំងមូល) ។

ឯរូបទេវតាកាន់ក្រាំងនោះ មានអធិប្បាយថា ទេវតាក្នុងទីនេះបានដល់ឧបបត្តិទៅ ឬសម្មតិទៅ ទាំងពីរផ្នែក គឺសូមឲ្យទេវតាសុទ្ធ ៗ នោះជួយពិនិត្យពិច័យថែទាំព្រះពុទ្ធសាសនាដោយពេញកំឡាំង កុំឲ្យប្រែប្រួលបាកពុទ្ធឱវាទឡើយ ។ ឯសម្មតិទៅ មានព្រះរាជាជាដើម ក៏ត្រូវផ្ទៀងផ្ទាត់ច្បាប់សាសនា ឲ្យហ្មត់ចត់កុំឲ្យឃ្លាតទៅណា ឲ្យដូចឱវាទដែលលិខិតទុកក្នុងក្រាំង តែងតែមិនប្រែប្រួលបាកច្បាប់ដើម ។ ព្រោះហេតុនោះ បានជារូបទេវតាដែលគេធ្វើនោះ មានសណ្ឋានដូចជាប្រឹងផ្ទៀងក្រាំងនោះណាស់ នេះជាប្រស្នាទី ២ ។ ឯរូបព្រះនារាយណ៍នោះ ឥតជាប្រស្នាអ្វីទេ ធ្វើដោយការច្រឡំ ព្រោះព្រះនារាយណ៍នេះ ជាព្រះមួយអង្គ ក្នុងសាសនាព្រាហ្មណ៍ ប្រទេសយើងពីដើមធ្លាប់កាន់សាសនាព្រាហ្មណ៍ ម្ល៉ោះហើយក៏ធ្វើទៅឥតមានគិតគូរដល់ប្រស្នាអ្វីឡើយ ឬក៏ចង់ល្អមើល ។

វិហារដែលធ្វើរួចហើយ គេធ្វើបុណ្យដារឆ្លងជាមុន ឬបញ្ចុះសីមាតែម្តងទៅក៏បាន ។ ឯរបៀបបញ្ចុះសីមានេះគេត្រូវជីករណ្តៅ ៨ ក្នុងវិហារគ្រប់ទិសទាំង ៨ ហើយយកថ្ម ៨ ដុំ មកស្អិតស្អាងឲ្យមូលទុកធ្វើជាឫសសីមា ហើយស្រោបចងដោយអម្បោះស ហើយដំកល់ទុកក្បែរមាត់រណ្តៅ ហើយបាននិមន្តព្រះសង្ឃទាំង ៨ ទិសមកសូត្របញ្ចាន់តាកងតាមវិន័យកម្ម លុះបានឫក្សពារល្អក៏កាត់ដុំថ្មនោះ ទម្លាក់ទៅក្នុងរណ្តៅទៅ ។

ឯឧបាសកឧបាសិកាដើមវត្ត ឬអ្នកដែលមកពីជិតឆ្ងាយបានធ្វើបុណ្យប្រគេនបង្ហាន់ដល់ព្រះសង្ឃ ដែលបាននិមន្តមកកាន់ទិសសីមារបស់ខ្លួន ៗ ព្រោះរបៀបបុណ្យនេះ មានគេធ្វើកាន់ទិសសីមា មួយទិសម្នាក់ តាមពួកតាមក្រុមមនុស្សច្រើនតិច ៗ ឯកំណត់បុណ្យយូរថ្ងៃ ឬតិចថ្ងៃឥតកំណត់ទេ តាមសទ្ធារបស់ពុទ្ធបរិស័ទអ្នកធ្វើ ៗ អារាមដែលសាងដំបូងមានភិក្ខុសង្ឃចំនួន ៤-៥-៦ អង្គប៉ុណ្ណោះ ឥតមានកំណត់ថា ប៉ុណ្ណោះប៉ុណ្ណោះឡើយ ព្រោះអារាមថ្មីឥតមានកុលបុត្រប្រកបដោយសទ្ធាចង់បួសទេ ៗ ឯអាគន្តុកភិក្ខុទៀតក៏គ្មាន មកពីអារាមសាងថ្មីគ្មានការរៀនសូត្រពុទ្ធវចនដោយមាំទាំ ម្ល៉ោះហើយទើបមានព្រះសង្ឃតែ ៤-៥-អង្គ ជាអ្នកមេគំនិត ក្នុងកិច្ចកសាងអារាមថ្មីមុនគេនោះឯង មិនតែប៉ុណ្ណោះអារាមថ្មី មិនសូវសម្បូណ៌សេនាសនៈផង ៗ

សេចក្ដីប៉ុណ្ណោះជាសាវតារ អំពីរបៀបសាងអារាមក្នុងសាសនា ៗ

រឿងសាវតារវត្តនេះ បានសួរបញ្ជាក់អំពីអ្នកអាចារ្យ ប៉ែន-ទូត, ជាអាចារ្យសម្រាប់វត្ត ធម្មិស្សរារាម ឃុំរលួស ស្រុកសូទ្រនិគម ខែត្រសៀមរាប ៗ

ចប់

---

# បញ្ហាការសិក្សាដប់ពីរ

របស់អ្នកប្រាជ្ញបុរាណដែលបានដំណាលតៗមក

## ឃុនបណ្ណានុរក្ស ប៊ូ-ប៊ូ ទៀងពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

---

១ – បរិភោគអ្វីមិនចេះឆ្អែត?

ឆ្លើយថា: សេចក្ដីលោភគឺការចង់មាន ចង់បាន ចង់ល្អ ចង់សុខ មិនចេះអស់ មិនចេះផុត បើទុកជាទីងមានទីងបានដល់ប៉ុន្មានៗក៏នៅតែមិនល្មមមិនគ្រប់គ្រាន់ ត្រូវនឹងពាក្យថា " បរិភោគប៉ុន្មានមិនបាត់ឃ្លាន " ។

២ – ដេកព្រឹនមិនចេះភ្ញាក់ បានដល់អ្វី?

ឆ្លើយថា: បានដល់មោហៈគឺសេចក្ដីវង្វេង ។ វង្វេងស្រឡាញ់, វង្វេងស្អប់, វង្វេងល្អ, វង្វេងអាក្រក់, វង្វេងលាភ, វង្វេងយស, វង្វេងគេ, វង្វេងយើង ស្រវឹងទៅដោយសេចក្ដីវង្វេងគគពេលស្វាង គគពេលភ្ញាក់ ដូចមនុស្សដេកលក់គ្មានវេលានឹងប្រែត្រឡប់ខ្លួនពីមោហៈចេញបាន ។

៣ – ស្រឡាញ់អ្នកដទៃក្រៃលែងជាងស្រឡាញ់ខ្លួនឯងព្រោះអ្វី?

ឆ្លើយថា: ព្រោះមានមោហៈនោះឯង ជាហេតុបណ្ដាលឲ្យស្រឡាញ់អ្នកដទៃក្រៃលែងជាងខ្លួនឯង គឺស្រឡាញ់ប្ដី ស្រឡាញ់ប្រពន្ធ ស្រឡាញ់កូន ស្រឡាញ់ចៅ ស្រឡាញ់មិត្តភក្ដិ ស្រឡាញ់

ទៅហាយនាយ ទាល់តែបណ្ដាយខ្លួនឲ្យធ្លាក់ចុះទៅក្នុងអំពើអាក្រក់ផ្សេងៗ មានសម្លាប់សត្វ លួចទ្រព្យគេ និយាយកុហកបោកប្រាស់យកទ្រព្យសម្បត្តិអ្នកដទៃ មកទំនុកបម្រុងបំពេញចិត្តរបស់ខ្លួនទាំងនោះ ខ្លួនឯងក៏ទទួលផលអកុសលនោះតែម្នាក់ឯង ព្រោះតែសេចក្ដីស្រឡាញ់គេជាហេតុនាំឲ្យធ្វើអំពើអាក្រក់គ្រប់ប្រការ ។

៤ – របស់គួរខ្លាចបែរទៅជាហ៊ាន ព្រោះអ្វីជាហេតុ?

ឆ្លើយថា: ព្រោះតែសេចក្ដីស្រឡាញ់អ្នកដទៃនោះឯងជាហេតុ ។ អំពើអាក្រក់ជារបស់មនុស្សអ្នកខ្លាច ប៉ុន្តែអ្នកនោះត្រឡប់ទៅជាហ៊ានធ្វើគ្រប់ប្រការវិញ គឺថាមនុស្សមានជាតិស្មើគ្នាក៏ហ៊ានសម្លាប់ សត្វធំឬតូចមានគុណឬឥតគុណក៏ហ៊ានសម្លាប់ទាំងអស់ សូម្បីទ្រព្យសម្បត្តិរបស់អ្នកដទៃក៏ហ៊ានលួចយកដែរ ហ៊ាននិយាយកុហកបោកប្រាស់គេ ហ៊ានកាត់ក្តីខាងចាញ់ឲ្យឈ្នះខាងឈ្នះឲ្យចាញ់វិញ ឈ្មោះថាអំពើអាក្រក់ទាំងអស់ ទោះតែហ៊ានធ្វើគ្រប់មុខឥតសល់មិនបេះទើសទាល់ ព្រោះតែមោហៈនោះឯងជាហេតុ ។

៥ – របស់ខ្លីសំគាល់ថាជារបស់វែង តើបានដល់អ្វី?

ឆ្លើយថា បានដល់ជីវិតការរស់នៅរបស់សត្វត្រឹម ៦០ ឆ្នាំ ឬ ៧០ ឆ្នាំប៉ុណ្ណោះ ត្រូវចាត់ថាខ្លីណាស់តិចណាស់ ទាំងមិនមាននិមិត្តជាគ្រឿងសំ-គាល់ថាដល់ត្រឹមណោះត្រឹមណោះឡើយ ប៉ុន្តែសេចក្ដីប្រាថ្នានោះថា ហាក់

ដូចជានឹងរស់នៅកប់រយកប់ពាន់ឆ្នាំ គឺខំប្រឹងធ្វើការងារនឹងក្តួចកាន់របស់មានវិញ្ញាណឥតវិញ្ញាណ មានកូនប្រពន្ធស្រែចម្ការបញ្ជរជំណាំ ស្រុកទេស គោក្របីជាដើមថា អាត្មាអញនឹងរស់នៅធ្វើជាម្ចាស់គ្រប់គ្រងរក្សាកប់ម៉ឺនឆ្នាំទៅមុខ មិនដឹងថាជីវិតជារបស់មានប្រមាណតិចជារបស់ខ្លីឡើយ ។

៦ — បកដូងយកមាត់ខាំ ធៀបនឹងអ្វី?

ឆ្លើយថា: ធម្មតាការបកដូងត្រូវតែប្រើកាំបិតឬប៉ូវថៅ ព្រោះជារបស់រឹង មិនដូច្នោះបែរជាយកមាត់ខាំដូងវិញ ឃើញថាខុសពីធម្មតារបស់លោក ដល់ទីបំផុតមុខជាមិនបានបរិភោគសាច់ដូងនោះទេ ប្រៀបដូចជាមគ្គផលនិព្វាន ធម្មតាលោកអ្នកបានសម្រេចមគ្គផលនិព្វានទាំងអស់លោកត្រូវយកសីលសមាធិបញ្ញាជាមគ្គប្រហារកិលេស ប្រៀបដូចជាកាំបិតប៉ូវថៅសម្រាប់កាប់បកសំបកដូង ចំណែកខ្លួនមិនយកសីលសមាធិ-បញ្ញាធ្វើជាអាវុធសម្រាប់ប្រហារកិលេសទេ បែរជាទៅយកវោហារមកធ្វើជាគ្រឿងប្រហារកិលេសវិញ អួតថាខ្លួនចេះចាំច្រើនណាស់ឈ្លាសវៃជាងអ្នក នឹងកាន់យកមគ្គផលនិព្វានដោយមាត់តែប៉ុណ្ណោះ; សម្រេចសេចក្តីថានឹងនៅតែប៉ុណ្ណោះឯងឥតបានមគ្គផលនិព្វានទេ ព្រោះខុសពីធម្មតា ។

៧ — បីកូនខ្ចីឱបរឹតទុកមិនជាក់ គឺអ្វី?

ឆ្លើយថា: រាងកាយនេះប្រៀបដូចកូនខ្ចី ព្រោះកូនខ្ចីជារបស់ដែលម្តាយឬអ្នកថែរក្សាថ្នាក់ថ្នមជាទីបំផុត មិនហ៊ានធ្វេសប្រហែសបណ្តែត

បណ្ដាយទេ នៅចាំពិភ័ក្ដិរក្សាទាំងថ្ងៃទាំងយប់ ចាំបញ្ចុកបាយផ្ដុតទឹកឲ្យ ស្លៀកពាក់សំពត់ខោអាវជានិច្ច ដូចម្ដេចមិញ ឯអត្តភាពរាងកាយយើងនេះ ក៏ដូច្នោះឯង អ្នកជាម្ចាស់ខ្លួនត្រូវតែថែរក្សាថ្នាក់ថ្នម បើឃ្លានត្រូវរកអាហារ ឲ្យបរិភោគ បើក្ដៅឲ្យងូតទឹក បើរងាឲ្យដណ្ដប់សំពត់ ទោះដើរទៅទីណាក៏ ចេះតែប្រុងប្រយ័ត្នមានឆ័ត្របាំងសម្រាប់ការពារកំដៅថ្ងៃនិងទឹកភ្លៀងមាន ស្បែកជើងពាក់ទៀត បើជាអ្នកជាន់ខ្ពស់មានយសស័ក្ដិធំនិងអ្នកមានទ្រព្យ សម្បត្តិច្រើនវេលាចេញពីផ្ទះទៅទីណា តែងតែជិះយានជំនិះផ្សេងៗថ្នាក់ថ្នម រាងកាយមិនហ៊ានដើរ ទាល់តែខូចកំឡាំងជើងអស់លែងដើរកើតតាំងពីខ្លួន នៅក្មេង ក្លាយទៅជាមនុស្សខ្វិនពិការក្វែងក្វង់ តែនឹងធ្វើប្រយោជន៍យ៉ាង សំខាន់ដល់ខ្លួន គឺរកធម៌ទីពឹងដល់ខ្លួនដូចជាការរក្សាឧបោសថសីលក៏ មិនកើត ដោយការខ្លាចឃ្លានបាយខ្លាចខ្យល់ចាប់ខ្លាចស្លាប់ពួកមនុស្សអ្នក ថ្នាក់ថ្នមរាងកាយដូចជាឧបរឹតយ៉ាងនេះ នឹងពួកមនុស្សដែលប្រកាន់ថារាង កាយកើតមកសម្រាប់ប្រើប្រាស់ ដូចជាជើងសម្រាប់ដើរជាដើម ៗ ឯ ឧបោសថសីល បើប្រសិនជាមនុស្សរក្សាមិនបានទេ មុខជាព្រះពុទ្ធអង្គមិន ទ្រង់អនុញ្ញាតទុកមកឡើយ ពួកអ្នករក្សាមកពីមុនក៏មិនឮដំណឹងថាអ្នកណា ស្លាប់ក្នុងថ្ងៃរក្សាឧបោសថដែរ គិតឃើញយ៉ាងនេះហើយគួរតែប្រព្រឹត្ត ទៅដោយធម្មតាតាមនាទី អាយុជីវិតរបស់មនុស្ស២ជំពូកនេះ ក៏មិនឃើញ ថាចាញ់ឈ្នះគ្នាច្រើនឬតិចប៉ុន្មាន ហេតុនោះកុំវង្វេងឧបរឹតពេកឡើយ ។

៨ — វង្វេងផ្លូវមិនសាកសួរ តើនឹងដល់ទីបំណងឬទេ ?

ឆ្លើយថា: ធម្មតាមនុស្សវង្វេងផ្លូវ បើជួបនឹងអ្នកណា ត្រូវតែសាកសួរ ចុះបើមិនសួរគេទេ មុខជាទៅមិនដល់ស្រុកភូមិដែលខ្លួនចង់ទៅ ចេះតែនៅរងទុក្ខលំបាកក្នុងផ្លូវដែលវង្វេងនោះ មានអត់បាយអត់ទឹកជាដើម ប្រៀបដូចបុគ្គលមិនស្គាល់ផ្លូវនរកផ្លូវសួគ៌ផ្លូវនិព្វានផ្លូវសុខផ្លូវទុក្ខ ចេះតែធ្វើបុកពារឹងត្អឹងអួតខ្លួនមិនព្រមសួរលោកអ្នកចេះដឹង គង់តែវង្វេងភ្លាត់ធ្លាក់ទៅខាងផ្លូវនរកក៏មាន កម្រនឹងដើរសំដៅឲ្យត្រង់ទៅលើផ្លូវសួគ៌និព្វានណាស់ គួរតែខ្លាចខ្ចួបជាតិកំណើត បើវង្វេងអស់មួយជីវិតគួរឲ្យស្តាយជាទីបំផុត ព្រោះមានមនុស្សដូចគ្នាជាច្រើនដែលគេចេះដឹងបានរកផ្លូវទៅដល់ស្ថានសុគតិសួគ៌ ចំណែកខ្លួនយើងនៅតែវង្វេងវិលវល់ បែរមុខទៅរកផ្លូវទុគ្គតិ គួរឲ្យស្តាយពេកណាស់ ។

៩ — គេចពីក្រពើធំភ្លាត់ចុះទឹក តើដូចម្តេច ?

ឆ្លើយថា: ក្រពើធំប្រៀបដូចសេចក្តីទុក្ខ មនុស្សខ្ពើមទុក្ខ ខ្លាចទុក្ខ គិតគេចចេញពីទុក្ខ ៗ ការគេចចេញពីទុក្ខនេះបែរជាភ្លាត់ទៅមានផ្ទះវិញ គឺទៅជាមានប្តីប្រពន្ធ ៗ ការគ្រប់គ្រងផ្ទះគឺមានប្តីប្រពន្ធនេះឯង លោកប្រៀបដូចទឹកដែលទុកជាផ្ទះជាទីលំនៅរបស់ក្រពើ តពីនោះទៅក៏នឹងមានតែទុក្ខតូចទុក្ខធំគឺក្រពើខាំពាំយកទៅ នឹងយកសុខស្អាតមកពីណា ព្រោះតែមិនដឹងផ្លូវសុខនោះឯងជាហេតុ ៗ

១០ - ត្រូវគុកច្រវាក់បែរទៅជាត្រេកអរវិញ តើដូចម្តេច?

ឆ្លើយថា: ទីកន្លែងនិងគ្រឿងប្រដាប់សម្រាប់ដាក់ទុកឃុំឃាំងអ្នកមានទោសសព្វថ្ងៃនេះជារបស់មាំទាំសំខាន់ណាស់ សុទ្ធតែធ្វើពីឥដ្ឋនិងដែក គឺខ្សែច្រវាក់ក ១ ខ្នោះដៃ ១ ខ្នោះជើង ១ ។ លោកសំដែងក្នុងច្បាប់ខ្ទះថា តណ្ហាសេចក្តីស្រឡាញ់កូនទុកដូចច្រវាក់ដែកមកចងក, តណ្ហាសេចក្តីស្រឡាញ់ប្តីស្រឡាញ់ប្រពន្ធទុកដូចខ្នោះដែកមកដាក់កដៃ, តណ្ហាសេចក្តីស្រឡាញ់សម្បត្តិទ្រព្យទុកដូចខ្នោះដែកមកដាក់កជើង តណ្ហា ៣ ប្រការនេះជាចំណងចងសត្វឲ្យវិលវល់នៅក្នុងវដ្តសង្សារ ត្រូវតែអាស្រ័យអរិយមគ្គញាណទើបនឹងកាត់ឲ្យដាច់បាន ។ អាស្រ័យន័យនេះឃើញត្រូវនឹងប្រស្នាថា "ត្រូវគុកច្រវាក់បែរទៅជាត្រេកអរវិញ" ។ ព្រោះថាបុគ្គលខ្លះទៅបើមានកូនមានប្តីមានប្រពន្ធមានសម្បត្តិទ្រព្យហើយ រមែងត្រេកអរទាំងរស់គ្នាជាច្រើននាក់ ។

១១ - គតាំងនឹងសត្រូវមិនរកអាវុធ តើឈ្មោះអ្វីទេ?

ឆ្លើយថា: ធម្មតាសត្រូវ គេតែងតែប្រុងប្រៀបអាវុធយុទ្ធភ័ណ្ឌឲ្យសព្វគ្រប់ ។ បើយើងតយុទ្ធនឹងសត្រូវ យើងក៏ត្រូវតែប្រុងប្រៀបអាវុធយុទ្ធភ័ណ្ឌទុកឲ្យមានសព្វគ្រប់ដែរ ទើបនឹងច្បាំងគ្នាបាន ។ រឿងនេះសំដៅយកចម្បាំងខាងក្រៅ ។ ក្នុងប្រស្នានេះលោកសំដៅយកចម្បាំងខាងក្នុង ។ ឯចម្បាំងខាងក្នុងមានមេសត្រូវតែ ៣ នាក់ប៉ុណ្ណោះ

គឺមេជក ១ មេព្យាធិ ១ មេមរណៈ ១ សុទ្ធតែជាមេកោងកាចអាក្រក់ណាស់ បំផ្លាញជីវិតរបស់មនុស្សនិងសត្វពេញលោកមិនចៀសវាងមុខឲ្យសល់ដល់ម្នាក់ឡើយ ។ យើងត្រូវតែប្រុងប្រៀបអាវុធខាងក្រៅទុកតដៃនឹងមេសត្រូវទាំង ២ គឺមេជកនឹងមេព្យាធិ ឯមេជកនោះឲ្យរកអាវុធគឺថ្នាំធ្វើឲ្យអាយុវែងទុកតនឹងវា ឯមេព្យាធិនោះត្រូវប្រើថ្នាំផ្សេង ៗ ព្រោះវាមានអំណាចអាចសំដែងឫទ្ធិបានដល់ ៩៦ ប្រការ ។ បើដឹងថាច្បាំងដោយអាវុធគឺថ្នាំមិនឈ្នះហើយ ត្រូវចូលចិត្តថាសត្រូវមេកំឡាំងគ្នាបានហើយ គឺមេមរណៈបានមេជកនឹងមេព្យាធិមកជាកំឡាំងពេញទីហើយ អាវុធខាងក្រៅច្បាំងលែងកើតហើយ ត្រូវតែយកអាវុធខាងក្នុងចេញមកច្បាំង ។ ឯអាវុធខាងក្នុងនោះគឺបញ្ញាវុធ វេលានេះយើងត្រូវយកជ័យជំនះឲ្យទាល់តែបាន ឲ្យត្រួតត្រាមើលកងទ័ពស្បៀង គឺទានដែលយើងបរិច្ចាគបច្ច័យទាំង ៤ ដល់លោកអ្នកមានសីលមានបរិបូណ៌ហើយឬនៅ? កំឡាំងទ្រព្យរបស់យើងតើដូចម្ដេច? សទ្ធាធនំ = ទ្រព្យគឺសទ្ធាជឿបញ្ញាត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធមានក្នុងខ្លួនយើងហើយឬ? សីលធនំ = ទ្រព្យគឺសីលមានក្នុងខ្លួនយើងហើយឬ? សង្ឃេ បសាទោ = សេចក្ដីជ្រះថ្លាក្នុងព្រះសង្ឃមានក្នុងខ្លួនយើងហើយឬ? ឧជុភូតញ្ច ទស្សនំ = សេចក្ដីឃើញត្រង់ក្នុងធម៌ដូច្នោះជាគួបញ្ញាធនំកើតឡើងដល់យើងហើយឬ? ។ កាលបើត្រួតត្រាមើលអរិយទ្រព្យឃើញថាមានគ្រប់គ្រាន់ក្នុងខ្លួនដូច្នេះ

ហើយ យើងក៏ដឹងបានថា កំឡាំងទ្រព្យកំឡាំងពាហនៈរបស់យើង មានបរិបូណ៌ហើយ កម្លាំងអាវុធគឺបញ្ញាជារបស់សំខាន់យើងក៏មានព្រមហើយ ៗ កាលពិនិត្យមើលឃើញកម្លាំងស្បៀង កម្លាំងទ្រព្យ កម្លាំងពាហនៈ កម្លាំងបញ្ញាមានសព្វគ្រប់ដូច្នេះហើយ មិនត្រូវខ្លាចដល់សត្រូវនោះឡើយ ចេញទៅឈរពីមុខកងទ័ពហើយចង្អុលមុខសត្រូវស្រែកប្រាប់ថា រុំយជរា! ព្យាធិ! មរណៈ! អញស្គាល់មុខមាត់អាច្បាស់លាស់ហើយ អាឯងទៅសំដែងឫទ្ធិឲ្យមនុស្សឆោតល្ងង់ខ្លៅឯណាចុះ កុំមកអួតអាងនឹងអញឡើយ ខ្លួនឯងគេគ្រាន់តែសន្មតថាសង្ខារប៉ុណ្ណោះទេ ឯងស្គាល់អញឬទេ បើមិនស្គាល់ អញនឹងប្រាប់ឲ្យដឹង ខ្លួនអញនេះគឺជាម្ចាស់ អមតៈ ជាជាតិកាយសិទ្ធ គ្មានជរា គ្មានព្យាធិគ្មានមរណៈ ពួកឯងតាមអញមិនទាន់ទេ ឯងយកតែសំបកនគរទទេទៅចុះ" ៗ នេះឯងជាអាវុធខាងក្នុងសម្រាប់ធ្វើសង្គ្រាមនឹងសត្រូវ ពួកអ្នកប្រាជ្ញលោកប្រឹងប្រៀបទុកគ្រប់គ្នា ៗ កាលបើយើងមិនរកអាវុធជ្រោះទុកសម្រាប់ខ្លួនទេ វេលាសឹកសត្រូវចូលមកដល់ យើងមិនចាញ់ដៃសត្រូវហើយឬ? ៗ

១២ – អ្នកណាមិនឈប់ មិនដល់ព្រះពុទ្ធ តើយ៉ាងណា?

ឆ្លើយថា: ពាក្យថា "ឈប់" ក្នុងទីនេះ មិនមែនសំដៅយកឈប់កាយកម្ម ឈប់វចីកម្ម ឈប់មនោកម្មទេ សំដៅយកត្រង់ការ

ឈប់គិត ឈប់ទឹក ឈប់រេរតព្រះពុទ្ធខាងក្រៅប៉ុណ្ណោះ ចំណែកកាយកម្ម វចីកម្ម មនោកម្ម ខាងទុច្ចរិតត្រូវតែទាញស្ពានចេញមិនឲ្យដើរឲ្យប្រកបតែដោយសុចរិតធម៌កល់វេលា - សូម្បីយើងទៅថ្វាយបង្គំព្រះពុទ្ធរូបឬព្រះធាតុចេតិយក្នុងអារាមក៏បាន ប៉ុន្តែឲ្យចូលចិត្តថា មិនមែនទៅរកព្រះពុទ្ធខាងក្រៅមកបំពេញព្រះពុទ្ធខាងក្នុងទេ គឺទៅបំពេញកិច្ចទស្សនានុត្តរិយៈរបស់ខ្លួនទេតើ បើដឹងយ៉ាងនេះហើយ សូម្បីទៅក៏ឈ្មោះថាឈប់ឈ្មោះថានៅជាមួយនឹងព្រះពុទ្ធគ្រប់កាល ។

ការឆ្លើយប្រស្នាទាំង ១២ យ៉ាងនេះ មិនប្រាថ្នានឹងឆ្លើយឲ្យត្រូវតាមបំណងរបស់អ្នកសួរទេ ឆ្លើយតែតាមសេចក្តីយល់ឃើញនឹងសេចក្តីពេញចិត្តរបស់អ្នកឆ្លើយប៉ុណ្ណោះ នឹងមិនប្រាថ្នាឆ្លើយឲ្យអ្នកមើលត្រូវចិត្តគ្រប់គ្នាទេ ប្រាថ្នាតែឲ្យអ្នកមើលអ្នកស្តាប់ពួកខ្លះកាន់យកប្រយោជន៍ចំណែកខ្លួនតែប៉ុណ្ណោះ បើឃើញថាជាប្រយោជន៍ចូលកាន់យកចុះ បើឃើញថាឥតប្រយោជន៍ចូរធ្វើចិត្តឲ្យជាកណ្តាលកុំចាប់ទោស ។

## ប្រកាន់ខុសជាត្រូវ
## ជាដួងវិនាសជាតិប្រទេស

អក្សរខ្មែរ ភាសាខ្មែរ សំពត់ខ្មែរ គុយទាវខ្មែរ ហាងខ្មែរ ការស្នាដៃខ្មែរ ប្រពន្ធឯង យល់ថាប្រើមិនថ្លៃខ្លួន បរិភោគមិនឆ្ងាញ់ ចូលទិញមិនស្និទ្ធ ៗ នេះហៅថាយល់ខុសជាត្រូវ ។

# រឿងសាមកុក

## ភាគទី ៨

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាត
ទាំងមានសន្តានស្នេហាជាតិ ។

បណ្ដាស្រីប្រុសចាស់ក្មេង ដែលចោរចាប់ទុកជាពួកម៉ាកគ្រប់តំបន់ ប្រហែល ១០០ ម៉ឺន, ចូឆូជ្រើសរើសយកតែរូបណា ដែលកាចសាហាវ ខ្លាំងពូកែទុកជាសេនាទាហាន បានប្រហែលជាង ២០ ម៉ឺន, រូបណា ដែលចាស់ជរាពិការទន់ស្រី ក៏ឲ្យត្រឡប់ទៅរកស៊ីធ្វើការតាមទីលំនៅរៀងខ្លួនវិញ ។

ចូឆូបកសំបុត្រចូលទៅក្រាបបង្គំទូលព្រះចៅហៀនតេថា " ទូលព្រះបង្គំខ្ញុំបានបង្ក្រាបពួកចោរកំណាចរាបទាបអស់ហើយ " ។ លីឈុយ គុយគី ទទួលសំបុត្រហើយ នាំឡើងក្រាបបង្គំទូលព្រះចៅហៀនតេៗ

ទ្រង់មានព្រះតម្រាស់ថា " បូឆូគ្រានេះមានសេចក្ដីគាប់ប្រសើរក្នុងរាជការច្រើនណាស់ " រួចទ្រង់ត្រាស់ឲ្យមានព្រះរាជប្រកាសតាំងបូឆូជាទីមន្ត្រីធំជាងចៅហ្វាយខែត្រទិសខាងកើតទាំងអស់ ។ លីឈុយគុយគឺមិនបានជាគិតវែងឆ្ងាយ ក៏ធ្វើសំបុត្រតាំងបូឆូតាមក្រសែព្រះរាជឱង្ការ ។ កាលបូឆូបានជាធំតាមព្រះតម្រាស់ហើយ ក៏លើកទ័ពទៅតាំងនៅស្រុកគុនជីវ ហើយបញ្ចុះបញ្ចូលពួកម៉ាកនឹងរើសរកអ្នកមានគំនិតប្រាជ្ញាទុកជាទីប្រឹក្សា ។ បណ្ដាមនុស្សម្នាក្នុងអាណាខែត្រទាំងនោះ សឹងតែចុះចូលមូលមកជាពួកម៉ាកបូឆូច្រើនណាស់ ។

មានថ្ងៃមួយ ស៊ុនហុកជាមាស៊ុនស៊ីវដែលនៅនឹងអ្នូនសៀវនោះប្រឹក្សាគ្នាថា អ្នូនសៀវជាមនុស្សទុច្ចរិតអាក្រក់ យើងនឹងជ្រកនៅតទៅទៀតមិនបានទេ; ឥឡូវអាណាខែត្រទិសខាងកើតទាំងអស់ បូឆូបានជាធំត្រួតត្រាអស់ហើយ បណ្ដាមនុស្សក៏សឹងចុះចូលជាច្រើន យើងត្រូវតែចូលទៅនៅទីពឹងបូឆូវិញស្រួលជាង ។ ស៊ុនស៊ីវជាក្មួយយល់ឃើញត្រូវផង ក៏នាំគ្នារត់ចេញពីអ្នូនសៀវទៅនៅនឹងបូឆូឯស្រុកគុនជីវ ។ បូឆូឃើញស៊ុនហុក ស៊ុនស៊ីវ អង់អាចមុតមាំណាស់ ទំនងដូចជាមានសតិប្បញ្ញាខ្លាំងពូកែ ហៅចូលទៅសួរហើយតាំងទុកជាទីប្រឹក្សា ។ ស៊ុនហុកជំរាបបូឆូថា ខ្ញុំបាទបានឮគេនិយាយថាជៀយ៉ុកជាពួកស្រុកតុងគុននោះមានសតិប្បញ្ញាណាស់ ឥឡូវនេះមកនៅស្រុកគុនជីវនេះ ហេតុម្ដេចក៏

លោកមិនល្បងយកមកផង? ។ ប្ដូថា "យើងក៏បានឮគេនិយាយល្បីល្បាញមកជាយូរហើយ តែយើងមិនទាន់ដែលឃើញខ្លួនសោះ" ថាហើយក៏ប្រើមនុស្សឲ្យទៅស៊ើបរកខ្លួនធៀយ៉ុកល្បងនាំបានមក ។ ប្ដូបានឃើញធៀយ៉ុកក៏មានចិត្តស្រឡាញ់ជាពន្ទឹក ទើបតាំងធៀយ៉ុកទុកជាទីប្រឹក្សា ។

ឯធៀយ៉ុកដឹងថា ស៊ិនហុកស្នើសេចក្ដីគុណគាប់របស់ខ្លួនឲ្យប្ដូដឹងដូច្នោះ ក៏មានសេចក្ដីអរគុណនឹងស៊ិនហុកច្រើនហើយថា ខ្លួនខ្ញុំនេះមានសតិបញ្ញាតិចណាស់ បើគុយកៃដែលនៅស្រុកជាមួយនឹងអ្នកនោះទើបមានសតិបញ្ញាច្រើន ហេតុម្ដេចអ្នកមិនស្នើឲ្យយកខ្លួនគុយកៃមកធ្វើរាជការផង? ។ ស៊ិនហុកឆ្លើយថា ខ្ញុំភ្លេចទៅហើយ ទាល់តែអ្នកនាំនឹក ឥឡូវនេះខ្ញុំក៏លើកឡើងបាន ។ ស៊ិនហុកបានយកសេចក្ដីនោះទៅជំរាបប្ដូៗ ឲ្យទៅយកខ្លួនគុយកៃមក ។ គុយកៃជំរាបប្ដូថា ឡៅហ៊ួជាពូជព្រះរាជវង្សព្រះចៅហាន់កង់ប៊ូ ១ បួនថុងពួកអ្នកស្រុកសាន់យ៉ុង ១ លីតៀនពួកអ្នកស្រុកប៊ូសេង ១ ម៉ាកាយពួកអ្នកស្រុកតាន់លីវ ១ ទាំង ៤ នាក់នេះមានសតិបញ្ញាច្រើន ។ ប្ដូចាត់ឲ្យទៅបញ្ចុះបញ្ចូលឈ្មោះទាំង ៤ នាក់នោះបានមកទៀត ហើយតាំងទុកជាទីប្រឹក្សា ។

ឯអ៊ីគិមពួកអ្នកស្រុកគីប៉េង ដែលជាចោរមានបក្សពួកច្រើន ក៏នាំយកបក្សពួកចូលមកនៅជាទាហានប្ដូទាំងអស់ ។ ហែហូទុននាំតៀនអ៊ុយ

មកនៅជាពួកចូចូទៀត ហើយដំរាបថា គៀនអ៊ុយនេះជាពួកអ្នកស្រុក តាន់លីវមានកំឡាំងខ្លាំងពូកែណាស់ សម្លាប់បាវព្រាវតៀវមៅអស់ជាច្រើន ហើយរត់ទៅនៅព្រៃ, ខ្ញុំបាទចេញទៅដើរលេងឃើញគៀនអ៊ុយវាយខ្លាស្លាប់ ហើយហៃលឆ្លងសមុទ្រមកជួបនឹងខ្ញុំបាទៗ ឃើញសមគួរជាទាហានណាស់ ក៏ល្បួងលួងលោមឲ្យមកនៅនឹងលោក ។ ចូចូបានស្ដាប់ពិនិត្យមើលរូបភាពគៀនអ៊ុយ ឃើញរូបរាងធំមាំមួនសមគួរជាទាហាន ទើបសួរបញ្ជាក់គៀនអ៊ុយថា បើខ្លួនធ្វើទាហាននោះតើនឹងចូលចិត្តកាន់ប្រដាប់អ្វីជាអាវុធ? ។ គៀនអ៊ុយឆ្លើយថា ខ្ញុំបាទធ្លាប់ចំណាននខាងកាន់ទួនផ្លែ ២ ទម្ងន់ ៨០ ជញ្ជីងចិន មានសម្រាប់ខ្លួនខ្ញុំបានហើយ ។ ចូចូបានព្រាត់ឲ្យរកសេះជំនិះ ១ មានថ្វីជើងពូកែ ឲ្យគៀនអ៊ុយឡើងជិះរំទួនល្បងមើល ។ ចូចូឃើញគៀនអ៊ុយជិះសេះរំទួនវេហ៊ាសវេហួនយ៉ាងចំណាប់ក្រឡេកមើលទៅឃើញដងទង់ជ័យ សម្រាប់ទ័ពដែលលើកទុកនៅមុខទ្វារស្រុកត្រូវខ្យល់ព្យុះទែកបុះនឹងរលំ មានទាហាន ២៥ នាក់កំពុងប្រានលើកឡើងក៏មិនទាន់កំរើក ចូចូប្រើគៀនអ៊ុយឲ្យទៅជួយលើក ។ គៀនអ៊ុយលោតចុះពីលើសេះរត់ទៅដេញទាហានទាំងនោះឲ្យដើរចេញ គៀនអ៊ុយចូលទៅលើកដងទង់នោះតម្រង់ឈរឡើងដូចដើម ។ ចូចូឃើញដូច្នោះក៏សរសើរគៀនអ៊ុយថាមានកំឡាំងដូចមនុស្សពីបុរាណ ហើយចាត់គ្រឿងក្រោះដែក ១ ប្រដាប់ឲ្យគៀនអ៊ុយ តាំងជានាយទាហានសម្រាប់រក្សាខ្លួនចូចូ ។

# វគ្គទី ៩

តាំងពីគៀវ យើសម្លាប់ច្ចក្ក ហើយអេងគៀវនាំទាហានរត់ទៅនៅនឹងអ្នកសៀវចៅហ្វាយស្រុកគិជីវ លុះផល់បីចៅចាត់ប្រើក្វូស៊ុន ដុនសុក និងហៅសេង លើកទាហានទៅរកក្បួនបត្តាយទ័ពឯណិចយ៉ាងមាំមួន ។

---

កាលដែលប៊ូឆ្វបានបញ្ចុះបញ្ចូលមនុស្ស ជាពួកក្រុមសេនាទាហាន បានមនុស្សចុះចូលជាច្រើនព្រមទាំងទីប្រឹក្សា ប៊ូឆ្វមានសេចក្តីត្រេកអរពន់ប្រមាណណាស់ ឲ្យអេងគៀវកាន់សំបុត្រលើកទាហានទៅទទួលប៊ូក្វូជាបិតា ដែលនៅស្រុកតាន់លីវឲ្យមកនៅជាមួយនឹងខ្លួន ។ កាលអេងគៀវទៅដល់ហើយ ក៏ជូនសំបុត្រទៅប៊ូក្វូ ។ ឃើញសេចក្តីសំបុត្រសំគាល់ប្រាកដថាជាពាក្យបុត្ររបស់ខ្លួនមិនមានសង្ស័យ ទើបរៀបប្រមូលទ្រព្យរបស់ធ្ងន់ស្រាល បបួលប៊ូតេកនឹងបងប្អូនសាច់ញាតិប្រហែល ២០០ ប៉ាយ លើកទ្រព្យរបស់ទាំងអស់ផ្ទុករទេះ ១០០ លើកទៅនៅស្រុកគុនជីវ ។

លុះទៅដល់ជិតស្រុកគុនជីវហើយ ចៅហ្វាយស្រុកឈីជីវឈ្មោះតូគៀមជាមនុស្សចិត្តល្អ ធូរទូលាយស្រឡាញ់រាប់អានអ្នកទាំងពួង គិតឃើញថា នឹងចូលទៅនៅនឹងប៊ូឆ្វ លុះដឹងថាប៊ូឆ្វឲ្យទៅទទួលប៊ូក្វូជាបិតាមកដល់ជិតស្រុកឈីជីវហើយ ក៏មានសេចក្តីត្រេកអរចេញទៅគំនាប់ប៊ូក្វូ ហើយអញ្ជើញឲ្យចូលទៅសំណាក់ក្នុងស្រុកនោះ រួចឲ្យរៀបបាយទឹក

ចំណីអាហារឲ្យប្អូនខ្ញុំក្រុមគ្រួសារបរិភោគ ៗ ប្អូនឈប់សម្រាកនៅស្រុកនោះ ២ ថ្ងៃ រួចតួកៀមចាត់ប្រើតៀវឃើនខ្ញុំទាហាន ៥០០ ឲ្យជូនដំណើរប្អូនទៅស្រុកគុនជីវ ៗ លុះទៅដល់តំបន់ត្រហៃហ៊ុយ ទទួលពេលយប់ធ្លាក់ភ្លៀងធំ ប្អូនឲ្យឈប់សំណាក់អាស្រ័យក្នុងទីនោះ ហើយឲ្យតៀវឃើដែលឃុំទាហានជូនទៅនោះ ពាយទាហានពទ្ធឡោមយាមល្បាតជុំវិញពីក្រៅ លុះពេលកណ្តាលអធ្រាត្រស្ងាត់ តៀវឃើប្រឹក្សានឹងទាហានទាំងពួងថា កាលពីដើមយើងជាពួកចោរជួតក្បាលលឿង លុះមានគេមកប្រាប់ប្រាមយើងលើកលះព្យុហៈគាក្រក់ចេញចូលទៅនៅនឹងតូកៀម ៗ មិនមានឲ្យរបស់អ្វីសោះ ដែលយើងនឹងធ្វើជការជាមួយតទៅនោះឃើញថាមិនបានប្រយោជន៍អ្វីឥឡូវតូកៀមឲ្យយើងជូនដំណើរប្អូនមក ប្អូនមានទ្រព្យសម្បត្តិមាសប្រាក់ផ្ទុកពេញរទេះច្រើនណាស់ យើងត្រូវតែលបសម្លាប់ប្អូនចេញ ហើយយកទ្រព្យរបស់ទាំងអស់ នាំគ្នារត់ទៅនៅបែកក្នុងស្រួលជាង ៗ ទាហានទាំងអស់យល់ព្រមផង ភ្លៀងសោតក៏នៅពុំទាន់រាំង តៀវឃើលើកទាហានចូលទៅនឹងសម្លាប់ប្អូន ៗ បានឮស្នូរទាហានគឹកកងចូលមក ស្ទុះឡើងដឹកដៃភរិយាតូចរត់ទៅ ៗ ទទួលតៀវឃើហោមព័ទ្ធពីក្រៅជាប់ សម្លាប់ក្រោកប្អូនស្លាប់នៅទីនោះ កាប់ទាំងបក្សពួកប្អូនស្លាប់ដេរដាស ហើយក៏ជញ្ជូនយកទ្រព្យរបស់អស់គ្មានសល់ យកទាំងភ្លើងដុតកុដិអាភាមនៅទីនោះឆេះអស់ទៅទៀត ហើយក៏នាំបក្សពួកទៅជ្រកពួនក្នុងព្រៃគៀនក្ន ៗ

ឯអេង់តៀវកាលឃើញចូកូស្លាប់ហើយ ក៏គិតបារម្ភខ្លាចបួចូ ទើបតែទៅនៅទីង៉ូនសៀវចៅហ្វាយស្រុកគីជីវ ។ ពួកទាហានដែលនៅជាមួយទីងអេង់តៀវ ក៏នាំគ្នាតែត្រឡប់ទៅប្រាប់បួចូតាមដំណើរដែលមានមកពីដើម ហើយថាចូកូបិតាលោកដែលស្លាប់នោះ យើងខ្ញុំយល់ឃើញថាគួកៀមប្រើកលឧបាយឲ្យតៀវឃើនាំទាហានជូនដំណើរមក ហើយក្លែងលបសម្លាប់បិតាលោក យកទ្រព្យរបស់ទៅឲ្យគួកៀមជាប្រយោជន៍ជាមួយគ្នា ។ បួចូបានឮថាបិតាស្លាប់ក៏ទួញយំដំនុកអាល័យបិតា ទាល់តែដួលធ្លាក់ពីលើកៅអីបាត់ស្មារតីកន្ទីនោះ ។ ពួកទាហានបានឃើញដូច្នោះក៏ស្ទុះទៅគ្រាហ៍ត្រកងឡើងវិញ ។ បួចូលុះដឹងស្មារតីហើយ មានសេចក្តីខឹងខ្ញាំងណាស់ថា "ដែលគួកៀមធ្វើកលឧបាយសម្លាប់បិតាយើង និងក្រុមញាតិរបស់យើង វេលានេះយើងនឹងលើកពួកពលទាហានទៅសង្កត់យកស្រុកឈីជីវឲ្យរាបដូចផែនដី ទើបអស់សេចក្តីក្តៅ" ថាហើយក៏កេណ្ឌប្រមូលពលទាហានបានចំនួន ៣ ម៉ឺនប្រគល់ឲ្យស៊ុនហុកនឹងជៀយ៉ុក នៅរក្សាស្រុកគុនជីវ ។ ឯខ្លួនបួចូក៏កេណ្ឌទាហានជាច្រើន លើកជាក្បួនទ័ពទៅជិតស្រុកឈីជីវ ហើយឲ្យតាំងបន្ទាយរាយទ័ពជុំវិញ ចាត់ប្រើហែហួទុននឹងអ៉ីគិម, តៀនអ៊ុយ ឲ្យលើកទាហានជាកងមុខ បើរាយបានស្រុកឈីជីវហើយ ឲ្យសម្លាប់ឲ្យអស់ទាំងប្រុសទាំងស្រីកុំឲ្យសល់ទើបអស់កំហឹង ។

ខណៈនោះពៀនយៀង ចៅហ្វាយស្រុកគីវកាំង ដែលជាមិត្តស្និទ្ធស្នាលនឹងតូកៀម លុះបានដំណឹងថា ប៊ូឆូលើកទ័ពមកនឹងវាយយកស្រុកឈីជីវជូចោះ ក៏កេណ្ឌទាហាន ៥ ពាន់លើកទៅជួយតូកៀម ។ ប៊ូឆូបានដឹងដូច្នោះ ចាត់ប្រើហៃហូទុនឲ្យលើកទាហានទៅស្កាត់វាយទ័ពពៀនយៀងបានតទល់គ្នា ហៃហូទុនក៏ច្បាំងកាប់សម្លាប់ពៀនយៀងនឹងពលទាហានស្លាប់អស់ ។

ឯគាន់គុងដែលលបរត់ចោលប៊ូឆូពីគ្រាមុននោះ បានទៅសុំនៅធ្វើរាជការជាមួយនឹងចៅហ្វាយស្រុកតង់គុន ខុនគាន់គុងជាមិត្តស្និទ្ធស្នាលនឹងតូកៀមដែរ កាលបើឮដំណឹងថា ប៊ូឆូលើកទ័ពទៅវាយស្រុកឈីជីវជូចោះ ទាំងឮថាបើវាយស្រុកបានហើយ ឲ្យទាហានកាប់សម្លាប់មនុស្សទាំងប្រុសទាំងស្រីឲ្យអស់ គាន់គុងក៏ឡើងសេះតែម្នាក់ឯងស្រូតទៅទាំងយប់ទាំងថ្ងៃ ដើម្បីនឹងហាមឃាត់ប៊ូឆូកុំឲ្យធ្វើអន្តរាយតូកៀម លុះទៅដល់មុខបន្ទាយនិយាយប្រាប់ទាហានប៊ូឆូថា យើងសុំទៅជួបនឹងប៊ូឆូ ទាហានក៏ចូលទៅជំរាបប៊ូឆូ ៗ ដឹងហើយនឹកក្នុងចិត្តថា "ដែលគាន់គុងមករកយើងគ្រានេះមិនគឺអ្វី ប្រហែលមានការនិយាយពីរឿងតូកៀមជាប្រាកដ បើយើងមិនឲ្យចូលមកក៏បាន តែថាគេមានគុណូបការនឹងយើង កាលយើងរត់ពីតាំងតុ:, គាន់គុងនេះចាប់បានហើយមិនបញ្ជូនខ្លួនយើងទៅ បានជាយើងរស់រួចជីវិត" គិតហើយឲ្យទាហានហៅខ្លួនគាន់គុងចូលមក ៗ ប៊ូឆូគំនាប់ហើយ

សួរថា អ្នកមករកយើងនេះមានត្រូវការរឿងអ្វី? ។ គាត់កុងដំរាបថា ខ្ញុំដឹងថាលោកលើកទ័ពមកច្បាំងនឹងតួកៀម ប្រយោជន៍នឹងសងសឹក ព្រោះបិតាលោកស្លាប់, ឯតួកៀមចៅហ្វាយស្រុកឈើដីរនោះ ខ្ញុំបានស្គាល់ចិត្តនឹងគំនិតមារយាទជាមនុស្សសុចរិតពិតត្រង់ណាស់ បានប្រើគេរើយឲ្យនាំទាហានជូនដំណើរបិតាលោកទៅដល់តំបន់ហៃហ៊ុយ; ដែលកើតហេតុឡើងក្នុងទីនោះ ព្រោះគេរើយជាមនុស្សទុច្ចរិតចិត្តលោភសម្លាប់បិតាលោក យកទ្រព្យរបស់អស់ទៅហើយគេទៅពួនក្នុងព្រៃទាល់តែសម័យនេះ តួកៀមនឹងបានរួមគំនិតគិតឧបាយក្លាយក្លែងឲ្យធ្វើដូច្នោះក៏ទេ, ដែលលោកបង្គាប់ទាហានថាបើវាយបានស្រុកឈើដីរហើយ ឲ្យសម្លាប់ទាំងប្រុសទាំងស្រីឲ្យអស់នោះ ខ្ញុំឃើញថាអ្នកស្រុកនោះគ្មានទោសខុសអ្វីសោះ លោកនឹងឲ្យសម្លាប់នោះមិនគួរ, ដែលខ្ញុំដំរាបទាំងនេះសូមលោកត្រិះរិះមើលសិនចុះ ។

ប៉ូន្តុហើយខឹងប្រឡាតឡើងទៀតថា កាលយើងរត់ពីគាំងតុះមកនោះ អ្នកគិតព្រមល្មមទៅជាមួយយើង ហេតុម្តេចក៏រត់ចោលយើងកណ្តាលផ្លូវ ឥឡូវត្រឡប់មករកយើងវិញ; ឯតួកៀមប្រាកដជាប្រើឧបាយឲ្យជូនបិតាយើងទៅ ហើយក្លែងឲ្យសម្លាប់យកទ្រព្យរបស់ជាពិត, ហេតុនេះ ទើបយើងឈឺចិត្តលើកទ័ពមកសងសឹកតួកៀមវិញ ដែលអ្នកនឹងបែរមុខឃាត់ហាមយើងនោះ យើងមិនស្តាប់អ្នកទេ ។ គាត់កុងឃើញ

ចូឆូខឹងខ្លាំងណាស់ ក៏នៅស្ងៀមហើយលាចូឆូចេញពីបន្ទាយមកវិញ ហើយនឹកគិតតែក្នុងចិត្តថា "អញមកហាមឃាត់ចូឆូមិនសមដូចសេចក្ដីប្រាថ្នា បើនឹងទៅរកតូកៀមក៏បៀមចិត្តគួរគិតឲ្យអៀនខ្មាសណាស់" គិតហើយក៏ដើរត្រួតរះទៅរកតៀវម៉ៅនៅស្រុកតាន់លីវ ។

ឯចូឆូលើកទាហានទន្ទ្រានចូលទៅជិតស្រុកឈីជីវ ប្រទះនឹងមនុស្សប្រុសស្រីត្រង់កន្លែងណាក៏ឲ្យប្រហារឥតញញើតដៃសោះ ហើយឲ្យរឹបយកទ្រព្យរបស់មកទុកជាច្រើន ។

ខណៈនោះតូកៀមចៅហ្វាយស្រុកឈីជីវ ដែលដឹងថាចូឆូលើកទ័ពមកកាប់សម្លាប់អស់អ្នកស្រុកដូច្នោះ ក៏មានសេចក្ដីបរិវិតក្កកើតទុក្ខវេទនាសោកាទូញយំអាណិតអាណាប្រជានុរាស្ត្រពន់ប្រមាណ បានប្រជុំទីប្រឹក្សាពិចារណាយល់ឃើញថា ការណ៍ដែលកើតហេតុទាំងនេះ ព្រោះអកុសលកម្មរបស់យើងតាមមកទាន់ហើយ បានជាត្រូវអន្ដរាយស្លាប់គ្រប់គ្នា ។ ចូប៉ាឆ្លើយថាខ្លួនលោកគ្មានសេចក្ដីខុសអ្វីសោះ ឥឡូវនេះចូឆូលើកទ័ពមកធ្វើអន្ដរាយដូច្នេះ លោកចេះតែនៅស្ងៀមក៏ពុំកើត សត្រូវកាន់តែរំដួលឡើងទៀត ត្រូវយើងកេណ្ឌកងទ័ពត្រឡប់ទៅតតាំងច្បាំងគ្នាវិញទើបបាន ។ តូកៀមឃើញត្រូវផង ក៏តាំងកេណ្ឌទាហានបានក្នុងខណៈនោះ ដល់ព្រឹកឡើងឲ្យបើកទ្វារស្រុកលើកទាហានចេញទៅក្រឡេកទៅឃើញកងទ័ពចូឆូច្រើនលើសលប់ឧបមាដូចរលកសមុទ្រ ។

(មានត)

# ព្រះរាជពង្សាវតារប្រទេសកម្ពុជា

## ភាគទី ២

### សម័យនគរធំ

ឧកញ៉ាទេពពិទូរ ឈឹម - ក្រសេម រៀបរៀង

(តមក)

---

**ឱកាសរបស់ព្រះជ័យវរ្ម័ន** — វេលានោះរាជសម្បត្តិទំនេរ ។ ព្រះជ័យវរ្ម័នដែលទ្រង់រង់ចាំឱកាសអស់វេលា ១៨ ឆ្នាំហើយ ទ្រង់ឈ្វេងយល់ថា "វេលានេះ ដល់ពេលដែលទ្រង់ត្រូវចាត់ការស្រោចស្រង់ប្រទេសជាតិ ដែលលិចលង់មកយូរឆ្នាំនោះហើយ" ទើបទ្រង់រួបរួមសេនាទាហាន ហើយឡើងគ្រងរាជបល្ល័ង្ក តែពុំទាន់បានធ្វើព្រះរាជពិធីបរមរាជាភិសេកនៅឡើយ ។

**ការផែនដី** — ក្នុងសម័យដែលចាម្ប៉ាលុកលុយប្រទេសកម្ពុជាក្នុងឆ្នាំ គ.ស. ១១៧៧ នោះ ប្រាកដក្នុងសេចក្ដីកត់ហេតុរបស់អ្នកប្រវត្តិសាស្ត្រចិន ១ នាក់ ឈ្មោះម៉ាតួនលិនថា ព្រះជ័យវរ្ម័នបានទ្រង់ប្ដេជ្ញាក្នុងព្រះហឫទ័យថា នឹងធ្វើការសងសឹកចាម្ប៉ាវិញ ឲ្យល្បីល្បាញ, ហើយសេចក្ដីប្ដេជ្ញានោះបានសម្រេចយ៉ាងអស្ចារ្យ ក្នុងពេលក្រោយដែលទ្រង់អត់ទ្រាំមកអស់ ១៨ ឆ្នាំ ។

ប៉ុន្តែមុននឹងទ្រង់ប្រតិបត្តិការតាមព្រះរាជបញ្ញានោះ ទ្រង់ត្រូវការនឹងរម្ងាប់អសន្តិសុខដែលមាននៅក្នុងប្រទេសជាមុនសិន គឺក្នុងពេលនោះមានការណ៍បះបោរនៅតំបន់មល្យាង ដែលនៅជាខាងត្បូងខេត្តបាត់ដំបងសព្វថ្ងៃនេះ ។ ទ្រង់បានចាត់ព្រះរាជវង្សចាម្ប ១ អង្គព្រះនាម "វិទ្យានន្ទន៍" ដែលបានចូលមកជ្រកកោនក្រោមព្រះបរមពោធិសម្ភារ ឲ្យនាំទ័ពខ្មែរទៅកម្រាប ព្រះអង្គម្ចាស់នេះក៏ចាត់ការកម្រាបបានសម្រេច ។

ប្រវត្តិព្រះអង្គវិទ្យានន្ទន៍ ប្រាកដតាមសិលាចារិកនៅតំបន់មីសឺនថា "ព្រះអង្គម្ចាស់វិទ្យានន្ទន៍ជាព្រះរាជឱរសក្សត្រិយ៍ចាម្ប កាលនៅកុមារតូច ក្នុងឆ្នាំ ១១៨២ ទ្រង់បានចូលមកសុំជ្រកកោនក្រោមព្រះបរមពោធិសម្ភារនៃព្រះមហាក្សត្រិយ៍ខ្មែរ ។ ក្នុងគ្រានោះព្រះរាជាខ្មែរ គឺព្រះបាទជ័យវរ្ម័នទី ៧ ដែលទ្រង់ទើបនឹងបានគ្រងពិភពកម្ពុជា ទ្រង់សង្កេតឃើញថា "ព្រះអង្គម្ចាស់នេះប្រកបដោយលក្ខណៈល្អ" ព្រះអង្គក៏ទទួលចិញ្ចឹម ទ្រង់ស្រឡាញ់រាប់អានហាក់ដូចព្រះរាជឱរស ទ្រង់បានបង្រៀនចំណេះវិជ្ជាគ្រប់យ៉ាង ទាំងក្នុងវិទ្យាសាស្ត្រ ទាំងក្នុងយុទ្ធសាស្ត្រ ។

ក្នុងគ្រានោះ នៅតំបន់ស្រុក មល្យាង ដែលនៅជាខាងត្បូងខេត្តបាត់ដំបងសព្វថ្ងៃនេះ សឹងច្រើនតែជាមនុស្សអាក្រក់អាស្រ័យនៅ កើតបះបោរឡើង ។ ព្រះបាទជ័យវរ្ម័ន ត្រាស់បង្គាប់ឲ្យព្រះវិទ្យានន្ទន៍ដែលនៅចំទង់ឲ្យនាំទ័ពទៅកម្រាបពួកបះបោរនោះ ។ ព្រះវិទ្យានន្ទន៍បានចាត់ការ

កម្រាបអរិរាជសត្រូវឲ្យរាបទៅ តាមព្រះរាជបំណងនៃព្រះមហាក្សត្រិយ៍ ហើយនាំទ័ពត្រឡប់ព្រះនគរវិញ ដោយសុវត្ថិភាព ។ កាលព្រះរាជាទ្រង់ឃើញដំឡៃនឹងស្នាដៃព្រះវិទ្យានន្ទយ៉ាងនេះហើយ ក៏រឹងរិតតែសព្វព្រះរាជហឫទ័យឡើងទៀត, បានទ្រង់ព្រះមេត្តាប្រោសព្រះរាជទានយសជាយុវរាជ ព្រមទាំងទ្រព្យសម្បត្តិ នឹងគ្រឿងសប្បាយគ្រប់យ៉ាង ។ ព្រះវិទ្យានន្ទបានជាអាវុធដ៏សំខាន់ ក្នុងការសង់សឹកស្ដេចជយឥន្ទ្រវរ្ម័ន ទៅក្នុងថ្ងៃក្រោយ ។

កាលព្រះបាទជយវរ្ម័នទ្រង់ចាត់រៀបចំស្រុកទេស បានសាន្តត្រាណ ហើយក៏ទ្រង់នឹកដល់សេចក្ដីប្ដេជ្ញាដើម តែមុននឹងទ្រង់ចាត់ការតាមប្ដេជ្ញានោះ បានទ្រង់តែងរាជទូតឲ្យទៅសុំចងសម្ពន្ធមេត្រីភាព នឹងស្ដេចអណ្ណាមនៅក្រុងលីការ៉ុង ។ ស្ដេចយួនក៏ព្រមទទួលសម្ពន្ធមេត្រីភាពផង ព្រះមហាក្សត្រិយ៍ខ្មែរបានចងសម្ពន្ធមេត្រីភាពនឹងក្សត្រិយ៍យួន ជាគ្រាទី ២ ក្នុងរជ្ជកាលនេះ(១) ។

## សង្គ្រាមចាម្ប៍គ្រាទី ៦

ក្រោយនោះ ទ្រង់ក៏គិតលៃលករកឱកាសល្អដែលសង់សឹកចាម្ប៍ឲ្យដល់ខ្ចាត, ឱកាសល្អនេះ បានមានឡើងក្នុងឆ្នាំ ព. ស. ១៧៣៣ គ. ស. ១១៩០ ។ ដោយក្នុងពេលនោះព្រះជយឥន្ទ្រវរ្ម័នដែលយង់ឃ្នង

---

១ ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ២ បានចងសម្ពន្ធមេត្រីភាពជាគ្រាទី ១ ។

ដូចជាក្រុងកពណ៌ បានលើកទ័ពមកវាយប្រទេសកម្ពុជាម្ដងទៀត ជាគ្រាទី ៣ ។ កាលព្រះបាទជ័យវរ្ម័នទ្រង់ជ្រាបពត៌មានសឹកហើយ ត្រាស់ឲ្យព្រះវិទ្យានន្ទន៍កាន់កាប់ទ័ពស្រួច ចំណែកព្រះអង្គទ្រង់តំណែងជាមហាក្សត្រិយ៍សឹក កាន់កាប់ទ័ពហ្លួងលើកចេញទៅតទល់នឹងទ័ពព្រះជយឥន្ទ្រវរ្ម័ន ។ កងទ័ពខ្មែរបានដេញទ័ពចាម្ប៉ាខ្ចាត់ខ្ចាយ រត់ទៅក្រុងពិជ័យវិញ ។ ទ័ពខ្មែរក៏ដិតដោយតាមទៅដល់ក្រុងវិជ័យ ចាប់បានយក្សជយឥន្ទ្រវរ្ម័នទាំងរស់ ។

កាលស្រេចព្រះរាជសង្គ្រាមហើយ ទ្រង់តាំងព្រះរាជវង្ស ១ អង្គត្រូវជាព្រះអនុជថ្លៃរបស់ព្រះអង្គជាទីមហាឧបរាជ ឲ្យនៅគ្រប់គ្រងប្រ-ទេសចាម្ប៉ា ទឹង ទ្រង់ព្រះមេត្តាប្រោសតាំងព្រះវិទ្យានន្ទន៍ឲ្យនៅគ្រងខែត្រ បណ្ឌុរង្គ នៅខាងត្បូងក្រុងវិជ័យ គឺនៅស្រុកផានរ៉ាងសព្វថ្ងៃនេះ រួចហើយស្ដេចលើកទ័ពត្រឡប់ព្រះនគរ បានទាំងនាំយកព្រះជយឥន្ទ្រ-វរ្ម័នមកទុកជាឈ្លើយនៅព្រះនគរផង ។

ក្រោយដែលទ្រង់បានកម្រាបអសន្តិសុខក្នុងប្រទេស ទឹងក្រៅប្រទេសឲ្យស្ងប់សាន្តគ្រាណអស់វេលា ៤ ឆ្នាំមកហើយ ទើបទ្រង់ឲ្យធ្វើព្រះរាជពិធីបរមរាជាភិសេក នៅក្នុងឆ្នាំ ព.ស. ១៧២៤ (គ.ស. ១១៨១) ទ្រង់តាំងព្រះនាងជយរាជទេវី ជាអគ្គមហេសី ។

(មានត)

## ពិធីបុណ្យប្រគេនព្រហ្មទាន

### ចំពោះព្រះសង្ឃ ៨៨ រូបដែលប្រឡងជាប់សញ្ញាប័ត្រ
### សាលាបាលីជាន់ខ្ពស់

# ផ្សាយពីសមាគមមិត្តសាលាបាលី

---

កាលពីថ្ងៃទី ២៥ កុម្ភៈ គ.ស. ១៩៥១ នៅទីយ៉ សាលាបាលីជាន់ខ្ពស់មានពិធីបុណ្យមួយជាឧឡារិក គឺបុណ្យប្រគេនព្រហ្មទានដល់ព្រះសង្ឃ ៨៨ រូប ដែលទើបប្រឡងជាប់សញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ក្នុងឆ្នាំ ១៩៥១ នេះ ដែលកើតឡើងដោយសេចក្ដីណែនាំនៃសមាគមមិត្តសាលាបាលី ។

ពិធីបុណ្យនេះ បានប្រារព្ធធ្វើតាំងពីល្ងាចថ្ងៃទី ២៤ កុម្ភៈ ដោយរៀបចំរើនព្រះបរិត្ត មានព្រះសង្ឃនិងឥស្សរជនបាននិមន្តនិងអញ្ជើញទៅកាន់ពិធីនោះជាច្រើនរយ ៗ ដល់ម៉ោង ២១·៣០ នាទី ព្រះតេជព្រះគុណព្រះពោធិវង្សចាងហ្វាងសាលាបាលីជាន់ខ្ពស់ បានសំដែងធម្មទេសនាសរសើរផលនៃព្រហ្មទានជាដើម ព្រមទាំងពន្យល់អំពីបរិយាសម្បត្តិជាកិច្ចដាស់តឿនរំលឹកដល់ព្រះសង្ឃទាំងនោះ ឲ្យខំធ្វើអាកប្បកិរិយាឲ្យបានសមរម្យគួរជាទីជ្រះថ្លាដល់ពុទ្ធបរិស័ទតទៅអនាគត ៗ រួចហើយ, ឯកឧត្តម សម-ញាណ បានប្រកាសសេចក្ដីទទួលអំណរគុណចំពោះពុទ្ធបរិស័ទ តាងនាមសមាគមមិត្តសាលាបាលី និង អធិប្បាយរៀបរាប់

អំពីបំណងរបស់លោកចង់ពង្រីកមន្ទីរពុទ្ធសាសនបណ្ឌិត្យ ឲ្យបានទូលាយឡើង ល្មមជាទីទស្សនីយភាពនៃជនទាំងពួង ។

លុះព្រឹកឡើងថ្ងៃទី ២៥ ខែដដែល តាំងពីម៉ោង ១៦ ព្រះសង្ឃរាជាគណៈ ហំនាទុក្រម • ប្រមាណ ៥០០ រូប ព្រមទាំងឥស្សរជនទីងពុទ្ធបរិស័ទ្យបានទិមន្តអញ្ជើញទៅកាន់ពីធីបុណ្យនោះ ។ ចំណែកខាងព្រះសង្ឃ មានសម្ដេចព្រះសុធម្មាធិបតី សង្ឃនាយកវត្តបទុមវតីគណៈធម្មយុត្តិ, សម្ដេចព្រះធម្មលិខិតឧត្តមប្រឹក្សាវត្តលង្កា, សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ និងព្រះតេជព្រះគុណព្រះពោធិវ័ង្សជាដើម ។ ប៉ែកខាងឥស្សរជន គឺឯកឧត្តម អ៊ុំ-ឈាងស៊ុន ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ, ឯកឧត្តមញ៉ិក-ជូឡុង, ជាជិន-កុក, សម-ញាណ, ក្រៅពីនេះគឺ ឯកឧត្តម ស៊ុំហៀង, ពា៉-កាមុិល, សាន-យុន, ពា៉យ-លុត និង ប៉ាច-ឈឺន ជាដើម ។ យើងសូមអភ័យទោសដោយមិនបានពយនាមនៃអស់លោកដោយសព្វគ្រប់ ។

ដល់ពេលម៉ោង ៥ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានស្ដេចយាងទៅដល់យ៉សាលាបាលីជាន់ខ្ពស់ ដោយមានបរិពារតាមហែទ្រង់ទៅផង ហើយមានទាហានទីងភ្លេងជាតិចាំធ្វើគារវកិច្ច ។ ចំណែកព្រះសង្ឃទីងឥស្សរជនក៏រង់ចាំទទួលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។ លុះទ្រង់ប្រថាប់ហើយ, លោកអធិបតីសមាគមមិត្តសាលាបាលី បានថ្វេង

សុន្ទរកថាមួយទទួលអំណរព្រះមហាក្សត្រ នឹងរៀបរាប់អំពីវត្ថុបំណង របស់សមាគមមិត្តសាលាបាលី ដែលផ្គងជួយឧបត្ថម្ភការសិក្សាសាលាបាលីជាន់ខ្ពស់ ព្រមទាំងរៀបរាប់អំពីកិត្តិគុណនៃសាលានេះ ដោយលើកយកសេចក្ដីប្រៀបធៀបជាច្រើនប្រការមកបរិយាយ ។ លំដាប់តមកព្រះតេជព្រះគុណពោធិវង្សបានសូត្រសុន្ទរកថាមួយទៀត សរសើរផលនៃព្រហ្មទានដោយហេតុថាសាលាបាលីជាន់ខ្ពស់ បានកើតឡើង ៣៦ ឆ្នាំហើយ មិនដែលមានធ្វើពិធីបុកបែបនេះទេ ហើយនឹងប្រទានឱវាទដល់ព្រះសង្ឃដែលទើបប្រឡងជាប់នុះ ឲ្យខំព្យាយាមរៀនសូត្របន្តវិជ្ជាទៅទៀត ព្រមទាំងឲ្យខំអប់រំចរិយាសម្បត្តិឲ្យសមរម្យ គួរជាទីគោរពនឹងជាទិដ្ឋានុគតិដល់អ្នកទាំងពួង ព្រោះថាមនុស្សទាំងពួង ទោះបីបេះដូងយ៉ាងណាក៏ដោយ បើប្រាសចាកចរិយាសម្បត្តិហើយ នឹងទៅជាមនុស្សថ្លៃថ្នូរពុំបានឡើយ ។

បន្ទាប់មក ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ទ្រង់ប្រគេនសញ្ញាប័ត្រ នឹងព្រហ្មទានរបស់ទ្រង់ ដល់ព្រះមហា មាឃ-ឧក ដែលប្រឡងជាប់លេខ ១ ។ បន្ទាប់ពីនេះ ទើបអ្នកកាន់អង្គទាំងឡាយ ព្រមទាំងឥស្សរជន បានលើកព្រហ្មទានប្រគេនចំពោះព្រះសង្ឃ ជាលំដាប់ដល់លេខ ៤៨ ។ រួចហើយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ថ្វាយព្រះរាជសុន្ទរកថាមួយយ៉ាងសង្ខេប សរសើរអំពីវិរិយភាពនៃព្រះ

សង្ឃជាសិស្សានុសិស្សទាំងនោះ ដែលយើងយកមកចុះទាំងមូលជូនអ្នកអានដូចមានខាងក្រោយ ។

## បញ្ជាក់អំពីព្រហ្មទានដែលលើស

ព្រះសង្ឃដែលសមាគមមិត្តសាលាបាលីបានប្រកាសដល់អស់លោកសូមឲ្យជួយការអង្គនោះមានចំនួន ៨៨ រូប, ចំណែកព្រហ្មទានដែលបានមកចំនួន ១០៦ ឃើញលើសទេយ្យវត្ថុ ១៨ ។ រីឯទេយ្យវត្ថុដែលលើសនេះ បានមកដល់ពេលក្រោយដែលគណៈកម្មការរៀបចំដាក់លេខរង្វាន់នោះហើយស្រេច យើងបានវេរទេយ្យវត្ថុទាំងនោះ ទៅប្រគេនលោកគ្រូបង្រៀននឹងធម្មថិកសំដែងធម៌ ។ ដូចព្រហ្មទានរបស់ឃុនព្រះម៉ែនាងបុប្ផានរល័ក្ខណ៍ តាគ យើងបានប្រគេនទៅលោកគ្រូព្រះពោធិវង្សជាធម្មកថិក; ព្រហ្មទានពីរបស់លោកស្រីម្ចុះ ១, លោកអ៊ុងទិនអួន ១ យើងបានប្រគេនទៅលោកគ្រូបាងហ្វាងវង្សសាលាបាលីជាន់ខ្ពស់ នឹងលោកគ្រូអាចារ្យសុក្រសាស្ត្រាចារ្យបាលី ។ ព្រហ្មទានរបស់លោកអ៊ុច-រស ឧបាសិកាឡុង, ឯកឧត្តមមាសឯម, លោកសាម៉ន, ឧបាសិកាទិម, លោកយ៉ិប-ង្វួន, លោកប៊ុត-នាង, លោកអ៊ុក្រមពន្ធជាតិ, ចៅកែងឹង-ង្វួនហួត, លោកសីនសាន, លោកខុចអ្នកសយ, លោកម៉ៃ-ប៉ាន់, លោកយាយកែវ ទាំងអស់នេះ គណៈកម្មការបានប្រគេនលោកប្រឡងធ្លាក់ ៣ អង្គ នឹងសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ទាំងឡាយ ។

ឯសៀវភៅ "អស្សយុជបូជា, មាឃបូជា" ចំនួន ១០០ ក្បាល ជាព្រះរាជអំណោយព្រះករុណាជាម្ចាស់ជីវិតលើត្បូង សមាគមមិត្តសាលាបាលី បានយកទៅបញ្ចូលនឹងព្រហ្មទានពីទី ១ រហូតដល់ទី ៨៨ ។ ឯសៀវភៅសល់ ១២ នោះ សមាគមបានយកទៅដាក់បញ្ចូលក្នុងព្រហ្មទានដែលលើស ប្រគេនលោកសង្ឃ ៣ អង្គដែលប្រឡងធ្លាក់នឹងគ្រូបង្រៀន ។

បណ្ដាសៀវភៅរបស់ក្រុមពុទ្ធសាសនបណ្ឌិត្យ គឺបក្ខគណនាវិធី ៨៨ ក្បាល ស៊ុរិយាឡើងសក្ដិ ៨៨ ក្បាល នឹងពិធីទូទសមាស ១០ ក្បាល, សមាគមបានយកសៀវភៅបក្ខគណនាវិធីនឹងស៊ុរិយាឡើងសក្ដិមួយៗ ដាក់ក្នុងព្រហ្មទានពីលេខ ១ ដល់លេខ ៨៨, ឯសៀវភៅពិធីទូទសមាស ១០ ក្បាល បានយកទៅដាក់ក្នុងព្រហ្មទានតាំងពីទី ១ រហូតដល់ទី ១០ ។ ឯសៀវភៅច្បាប់ក្រមបរិយាយ ៥ ក្បាល របស់លោកមហាមន្ត្រី ញ៉ុក-នូ សមាគមបានយកទៅដាក់ក្នុងព្រហ្មទានទី ១ ដល់ទី ៥ ។ រីឯទៀតរបស់អ្នកម៉ែនាងកៀង, លោកឡាំ-ឯម, ស៊ិន-រ៉ាន់, ល-ដុន, សាម៉ន គណៈកម្មការបានយកទៅបញ្ចូលក្នុងព្រហ្មទានក្រៅពីនេះ ។

សុន្ទរកថា

# លោក វ៉ាយ-ប៊ុក អធិបតីសមាគមមិត្តសាលាបាលី

ថ្ងៃធ្វើបុណ្យប្រគេនព្រហ្មទាន ដល់សិស្សសាលាបាលីជាន់ខ្ពស់ នៅថ្ងៃ ២៥ កុម្ភៈ គ.ស. ១៩៥១ ។

សូមព្រះតេជៈដ៏កល់លើត្បូង

សូមព្រះរាជទានព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិត សូមទ្រង់ជ្រាប

ក្រោមល្អងធូលីព្រះបាទ ។

សូមថ្វាយបង្គំ សម្តេចព្រះសុធម្មាធិបតី សង្ឃនាយក,

— — សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា,

— — សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក,

— — ព្រះពោធិវ័ង្សប្រធានហ្វាងសាលាបាលីជាន់ខ្ពស់,

— — ព្រះថេរានុត្ថេរៈទាំងឡាយ,

សូមក្រាបទូលទ្រង់ទាំងឡាយ,

សូមជំរាប ឯកឧត្តមប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ,

— ឯកឧត្តមរដ្ឋមន្ត្រីទាំងឡាយ,

— លោកស្រីទាំងឡាយ,

— លោក-អ្នកទាំងឡាយ,

ទូលព្រះបង្គំជាខ្ញុំ, ខ្ញុំព្រះករុណា, ខ្ញុំប្របាទ, ខ្ញុំបាទ តាងនាមសមាគមមិត្តសាលាបាលី សូមព្រះរាជទានអភ័យទោសប្រកាសជាឧឡារិកចំពោះល្អងធូលីព្រះបាទ ថាថ្ងៃនេះជាថ្ងៃនក្ខត្តឫក្ស គឺពិធីបុណ្យចែកព្រហ្មទាន ដល់សិស្សដែលទើបប្រឡងជាប់សញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ក្នុងឆ្នាំ ១៩៥១ ។ ក្នុងឱកាសបុណ្យនេះ, ព្រះករុណាជាអម្ចាស់ជីវិតទ្រង់បានសំដែងទឹកព្រះទ័យជ្រះថ្លាដ៏ឧត្តម ដោយបានស្តេចយាងមកជាព្រះរាជាធិបតី ទុកជាព្រះរាជកិត្តិយសដ៏ប្រសើរបំផុត ចំពោះសមាគមមិត្តសាលាបាលី ដែលខំព្យាយាមបំពេញករណីយកិច្ចតាមវត្តុបំណង ដែលមានសំដែងក្នុងប្រការ ២ នៃលក្ខន្តិកៈ ថា "ឧបត្ថម្ភអក្សរសាស្ត្រភាសាបាលីនិងភាសាជាតិ ដោយសម្ភារៈនិងសីលធម៌" ។

វត្ថុបំណងនេះ បើពិចារណាតាមអត្ថនិងព្យញ្ជនៈ បានសេចក្តីថាវែងឆ្ងាយធូលាយ មានការឧបត្ថម្ភព្រះពុទ្ធសាសនាទូទៅទាំងកម្ពុជរដ្ឋទាំងមូលឲ្យមានកិត្យានុភាពពេញបរិបូណ៌ រហូតដល់ផ្សាយឥទ្ធិពលទៅនានាប្រទេសថែមទៀតផង ។ ព្រោះហេតុដូច្នេះ ការឧបត្ថម្ភនេះ ទុកជាកិច្ចមួយក្នុងភាគបួន ដែលសមាគមនេះត្រូវបំពេញតទៅទៀត តាមធនធានដែលគួរនិងធ្វើបានក្នុងអនាគត ។ បើទុកជាមានឧបសគ្គមករាំងរាយ៉ាងណា ក៏សមាគមនេះខំព្យាយាមធ្វើដំណើរការទៅតាមថ្នាក់តាមជាន់តស៊ូនិងឧបទ្ទវន្តរាយគ្រប់យ៉ាងដោយសុទ្ធចិត្ត ដើម្បីឲ្យបានសម្រេចទៅ

តាមវត្តបំណាន់ខាងលើ ។ តែកិច្ចការនេះដែលនឹងចំរើនទៅបាន លុះតែពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថ ទាំងក្នុងក្រុងនឹងខេត្តក្រៅ ក្នុងសាកលកម្ពុជរដ្ឋទាំងមូល មានសាមគ្គីធម៌ព្រមព្រៀងមូលមិត្តគ្នាជាឯកច្ឆន្ទ ជួយឧបត្ថម្ភការៈនេះតាមកម្លាំងទ្រព្យ កម្លាំងសតិបញ្ញាគ្រប់ៗគ្នា ។ ហេតុ នេះត្រូវទុកសមាគមនេះជាកម្លាំងមួយរបស់សាលាបាលីជាន់ខ្ពស់ ដែលជាព្រះកិត្តិយសនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់មានព្រះវីរិយភាពស្អាងវិជ្ជាស្ថានដ៏ឧត្តម សម្រាប់ផ្សាយកិត្តិស័ព្ទនៃព្រះពុទ្ធសាសនា នឹងអក្សរសាស្ត្រ, អភិបាលរក្សានូវភាសាបាលី នឹងភាសាជាតិព្រមទាំងវប្បធម៌ខ្មែរ, ទំនៀមទម្លាប់ខ្មែរ ឲ្យគង់ទ្រង់រហូតមកដល់សម័យបច្ចុប្បន្ននេះ ។ សាលាបាលីជាន់ខ្ពស់មិនមែនមានកិត្តិគុណត្រឹមប៉ុណ្ណោះទេ គឺជាសាលាមួយសម្រាប់អប់រំខាងគុរុវិជ្ជាផ្នែកសាសនានឹងអក្សរខ្មែរបាលី ដើម្បីនឹងផ្ទេរចំណេះនេះទៅជនជាតិខ្មែរគ្រប់ភូមិស្រុកនិគមជនបទក្នុងកម្ពុជរដ្ឋ ។ ព្រះសង្ឃទាំងនេះ ជាគ្រូអាចារ្យនៃជនជាតិខ្មែរដោយភាគច្រើន ព្រោះលោកតែងនិមន្តទៅទេសនាទូន្មានប្រដៅនូវធម៌វិន័យគ្រប់ច្រកល្ហកជានិរន្តរកាល ។ ព្រះមហាក្សត្រទុកជាវត្ថុធាតុដ៏ឧត្តម, សាលាបាលីជាន់ខ្ពស់ទុកជាដើមរុក្ខា, ព្រះសង្ឃជាបុប្ផាក្រអូប, ឧបាសកឧបាសិកា ជាឃ្មុំបុកទន់ដែលតែងជញ្ជក់នូវលំអងបុប្ផាទាំងនោះមកធ្វើសំបុក គឺចំណេះគ្រប់ៗគ្នា ។ បណ្ឌិតសម័យថ្មី

អាចពោលចំពោះកម្ពុជរដ្ឋថា "សាលាបាលីជាន់ខ្ពស់ជាខួរសិរសីនៃកម្ពុជរដ្ឋ" ដូចជាអ្នកប្រាជ្ញខាងអឺរ៉ុបគេធ្លាប់ពោលមកថា "ក្រុងប៉ារីសជាខួរសិរសីពិភពលោក" ដូចនោះ ។

ការជួយទំនុកបំរុងសមាគមមិត្តសាលាបាលី ឈ្មោះថាជួយទំនុកបំរុងសាលាបាលីជាន់ខ្ពស់និងសាលាបាលីរង តាមវត្តនានាក្នុងក្រុងនិងខេត្តក្រៅផង ឈ្មោះថាអប់រំព្រះសង្ឃ ដែលមានឋានៈជាមហាអាចារ្យឲ្យមានកាន់តែទ្វេចំនួនច្រើនឡើងរាល់ៗឆ្នាំផង ឈ្មោះថារចនាខ្លួនឲ្យមានវិជ្ជា ឲ្យមានពន្លឺភ្លឺស្វាងរុងរឿង ដើម្បីឲ្យភាសានិងអក្សរជាតិវិវត្តន៍ទៅកាន់វឌ្ឍនធម៌បានផង ។

ព្រោះសមាគមមិត្តសាលាបាលីយល់ឃើញថា សាលាបាលីជាន់ខ្ពស់ ជាវិជ្ជាស្ថានមួយដ៏ប្រសើរ អាចបណ្ដុះពូជបណ្ឌិតអ្នកប្រាជ្ញបាន ទើបបានជាផ្ដើមធ្វើបុណ្យប្រគេនព្រហ្មទាននេះ ដើម្បីនឹងញុំាងទឹកព្រះទ័យនៃព្រះសង្ឃដែលទើបបានប្រឡងជាប់និងព្រះសង្ឃដែលទើបប្រឡងចូលក្នុងឆ្នាំ ១៩៥១ នេះ ឲ្យមានឋាមភាពប្រកបដោយហសិតុប្បាទចិត្តដ៏ខ្លាំងក្លាឡើង ៗ ករណីយកិច្ចនេះ ជាប្រពៃណីនិយមដែលជនជាតិខាងបស្ចិមប្រទេសគេធ្លាប់ធ្វើមក ដើម្បីជារង្វាន់ដ៏វិសេសដល់សេចក្ដីព្យាយាមប្រឹងប្រែងនៃសិស្សទាំងនោះ ហើយជាគ្រឿងលើកទឹកចិត្តសម្រាប់ទាក់ចិត្តសិស្សដែលប្រឡងជាប់ ហើយឲ្យខំរៀនវិជ្ជាថ្នាក់ខ្ពស់ត

ទៅទៀតនឹងសិស្សដែលប្រឡងចូលទៅរៀន ឲ្យខំស្វាហាប់រៀនសូត្រវិទ្យានោះ ទាល់តែបានសម្រេចដូចបំណងគ្រប់ៗ គ្នា ដូចជាគ្រឿងឥស្សរិយយស ជាគ្រឿងស្ទូចលើកទឹកចិត្តសម្រាប់ទាក់ទាញនឹងទាញឲ្យបំពេញមុខការកាន់តែមាំមួនតទៅទៀត ៗ ។

ថ្ងៃនេះទុកជាថ្ងៃជ័យមង្គល សម្រាប់ឲ្យសិស្សដែលបានប្រឡងជាប់នឹកឮកជាអនុស្សាវរីយ៍ កងមនោទ្វារដ្ឋន: ដែលបញ្ចេញនូវសុភនិមិត្តអាចទស្សនាទៅហើយនាំឲ្យកើតបីតិបាមោជ្ជ: ប្រកបដោយអច្ឆរិយភាព, ក្រេចទឹកដល់ការព្រួយលំបាកនឿយហត់អត់ឃ្លានពីអតីតកាល ថែមទាំងឲ្យសិស្ស ដែលទើបប្រឡងចូលធ្វើមនសិការទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃថា នឹងព្យាយាមឲ្យពេញកម្លាំងដើម្បីនឹងសម្រេចផលនេះ ៗ

សមាគមមិត្តសាលាបាលី សូមថ្លែងកតញ្ញូកតវេទីចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់មានព្រះរាជហឫទ័យសោមនស្សខ្ពង់ខ្ពស់ចំពោះកិច្ចដែលសមាគមនេះបានធ្វើហើយ ជាជាកិច្ចមានសារៈប្រយោជន៍ចំពោះសាលាបាលីជាន់ខ្ពស់ផង ចំពោះពួកសិស្សសាលានេះផង ដោយព្រះរាជហឫទ័យស្មោះស្ម័គ្រនឹងការសិក្សាវិជ្ជាពុទ្ធសាសនា ហើយនឹងដោយព្រះអង្គទ្រង់ជាពុទ្ធសាសនូបត្ថម្ភកំពិតៗ ទ្រង់យកព្រះហឫទ័យទុកដាក់គ្រប់ផ្លូវគ្រប់ផ្នែក គ្រប់ថ្នាក់ ដោយព្រះមហាករុណាទិគុណដ៏ពន្លឺក ៗ សូមថ្លែងសេចក្តីអរគុណចំពោះសម្តេច, ទ្រង់, ព្រះតេជព្រះគុណ, លោក-អ្នក

ទាំងឡាយ ដែលមានសាមគ្គីធម៌មកជួយឧបត្ថម្ភការកុសលនេះឲ្យបាន សម្រេច ដោយយល់ថា សាលាបាលីជាន់ខ្ពស់ជាឃ្លាំងមួយធំ សម្រាប់តំកល់ទុកនូវវិជ្ជាខាងពុទ្ធសាសនានិងអក្សរសាស្ត្រខ្មែរ សម្រាប់ប្រជាជនខ្មែរ ត្រូវការសិក្សារៀនសូត្រតាមប្រាថ្នា, ម្យ៉ាងទៀតវិជ្ជានេះចាយណាស់ កាន់តែចំរើនណាស់, បរិភោគមិនចេះខ្ពើតខ្ពល់, បរិភោគណាស់ ឃ្លានណាស់ ។ កិត្តិគុណនៃសាលាបាលីជាន់ខ្ពស់មានជាអនេកបរិយាយ មិនអាចយកមកពណ៌នាឲ្យបានចប់សព្វគ្រប់ ព្រោះជាឃ្លាំងវិជ្ជាមិនចេះស្រកស្រុត ដូចទឹកសមុទ្រចេះតែពេញព្រៀបជានិច្ច ។

ក្នុងអវសាននេះ សមាគមមិត្តសាលាបាលី សូមឧទ្ទិសថ្វាយព្រះរាជកុសលដែលកើតដោយបុណ្យនេះ ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រមទាំងសម្ដេច, ព្រះតេជព្រះគុណគ្រប់អង្គ, ទ្រង់, ឯកឧត្តម, លោកអ្នកជាពុទ្ធមាមកជនទាំងឡាយ, ហើយសូមគុណានុភាពព្រះត្រៃរ័ត្ន ព្រមទាំងវត្ថុស័ក្ដិសិទ្ធក្នុងសាកលលោក និងផលានិសង្សនៃបុណ្យនេះ ប្រសិទ្ធិពរថ្វាយព្រះប្រិយមហាក្សត្រិយ៍ ទ្រង់គង់ជាសុខក្នុងសិរីរាជសម្បត្តិ ប្រកបដោយសួស្ដីជ័យមង្គលគ្រប់ជំពូក ព្រមទាំងព្រះរាជវង្សានុវង្ស អស់កាលជាយូរអង្វែងតទៅ ! សូមសម្ដេច, ព្រះតេជព្រះគុណ, ទ្រង់, លោកអ្នកជាពុទ្ធសាសនិកជនទាំងឡាយ បានសម្រេចនូវត្រៃពិធសម្បត្តិ ជាឥដ្ឋមនុញ្ញផល គឺ សម្បត្តិមនុស្ស ១ សម្បត្តិសួគ៌ ១ សម្បត្តិព្រះនិព្វាន ១ កុំបីឃ្លៀងឃ្លាតឡើយ ។ ។ (មាឧត)